ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# សេចក្តីព្រាង របាយការណ៍ស្តីពី
# ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
# នៅឆ្នាំសិក្សា ២០២០-២០២១
# នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង

អនុគណកម្មការបច្ចេកទេស

បញ្ចូលទិន្នន័យ វិភាគ និងសរសេររបាយការណ៍

បណ្ឌិត ង៉ាន់ ស៊ុនដេត

លោក សួន ចំរើន

ខែវិច្ឆិកា ឆ្នាំ២០២២

# មាតិកា

*តារាង* ........ *iii*

*ឧបសម្ព័ន្ធ* ........ *vi*

*សេចក្តីសង្ខេបលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា* ........ *1*

*ផ្នែកទី១. សេចក្តីផ្តើម* ........ *2*

១.១. សាវតារនៃការសិក្សា ........ 2

១.២. វត្ថុបំណងនៃការសិក្សា ........ 3

១.៣. ការប្រើប្រាស់លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា កន្លងមក ........ 3

*ផ្នែកទី២. វិធីសាស្ត្រនៃការសិក្សា* ........ *4*

២.១. វិធីសាស្ត្រប្រមូលទិន្នន័យ ........ 4

២.២. ក្រុមគោលដៅផ្តល់សម្ភាសន៍ (អ្នកចូលរួមឆ្លើយសំណួរនៃការសិក្សា) ........ 4

២.៣. ឧបករណ៍សម្រាប់ការសិក្សា និងការវិភាគទិន្នន័យ ........ 4

២.៤. វិសាលភាព និងដែនកំណត់នៃការសិក្សា ........ 4

២.៥. ក្រមសីលធម៌នៃការសិក្សា ........ 5

*ផ្នែកទី៣. លទ្ធផលនៃការសិក្សា* ........ *6*

៣.១. ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួម ........ 7

៣.១.១. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត ........ 7

៣.១.២. ចន្លោះអាយុរបស់និស្សិត ........ 8

៣.១.៣. អាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត ........ 9

៣.២. ព័ត៌មានពីការសិក្សា ........ 9

៣.២.១. ការចុះកម្មសិក្សា ឬហាត់ការ និងការទទួលបានប្រាក់ចំណូល ........ 9

៣.២.២. សេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាដែលអាចឆ្លើយតបទីផ្សារការងារ ........ 11

៣.៣. ព័ត៌មានពីកម្មវិធីសិក្សា ........ 12

៣.៤. ព័ត៌មានពីស្ថានភាពការងារ ........ 14

៣.៤.១. ប្រភេទការងាររបស់និស្សិត ........ 14

៣.៤.២. ប្រភេទនៃកិច្ចសន្យាការងារ ........ 15

៣.៤.៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន ........ 15

៣.៤.៤. ប្រភេទនៃស្ថាប័នអាជីវកម្មដែលនិស្សិតបញ្ចប់ការសិក្សាបាន និងកំពុងបំពេញការងារ ........ 16

៣.៤.៥. ការទទួលបានការងារធ្វើនៅកន្លែងការចុះកម្មសិក្សា ........ 17
៣.៤.៦. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ ........ 18
៣.៤.៧. ឋានៈការងារនៅក្នុងស្ថាប័ន ........ 19
៣.៤.៨. ភាពមានការងារធ្វើស្របជំនាញច្រើនជាង ឬតិចជាង៥០% នៃកម្មវិធីសិក្សា ........ 19
៣.៤.៩. ការទទួលបានប្រាក់ចំណូលប្រចាំខែ ........ 21
៣.៤.១០. ករណីនានាដែលមិនទាន់មានការងារធ្វើ ........ 22
៣.៤.១១. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា ........ 23
៣.៤.១២. ការចំណាយពេលដើម្បីទទួលបានការងារស្របជំនាញ ........ 23
៣.៤.១៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន ........ 24
**៣.៥. ព័ត៌មានពីតម្រូវការមុខជំនាញ ........ 26**
៣.៥.១. តម្រូវការបំណិនជំនាញសម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន ........ 26
៣.៥.២. ការប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារប្រចាំថ្ងៃ ........ 28
**៣.៦. ព័ត៌មានពីមតិយោបល់របស់អ្នកចូលរួម ........ 29**
៣.៦.១. ការជួយនិស្សិតដើម្បីទទួលបានការងារ ........ 29
៣.៦.២. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ ........ 29
៣.៦.៣. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត ........ 30
៣.៦.៤. ការសិក្សាជំនាញខ្លីៗ ........ 30
៣.៦.៥. ការចូលរួមសកម្មភាពសង្គម ........ 31
**ចំណុចខ្លាំង និងចំណុចខ្វះខាត នៃកម្មវិធីបណ្តុះបណ្តាល ........ 33**
***ផ្នែកទី៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 35***
**៤.១. ការសន្និដ្ឋាន ........ 35**
**៤.២. អានុសាសន៍ ........ 35**
**៤.៣. ការងារត្រូវធ្វើបន្ត និងសំណូមពរ ........ 35**
**៤.៤. គន្ថនិទ្ទេស (ឯកសារយោង) ដែលបានប្រើប្រាស់ក្នុងការសិក្សា ........ 36**
***ឧបសម្ព័ន្ធ ........ 37***

# តារាង

តារាង 1. ភាពមានការងារធ្វើរបស់និស្សិតឆ្នាំសិក្សា២០១៧-២០១៨ និងឆ្នាំសិក្សា២០២០-២០២១ ..... 6
តារាង 2. ភាពមានការងារធ្វើរបស់និស្សិតក្នុងអំឡុងពេល៦ឆ្នាំចុងក្រោយ (ឆ្នាំសិក្សាបញ្ចប់) ..... 6
តារាង 3. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត ..... 7
តារាង 4. ចន្លោះអាយុរបស់និស្សិត ..... 8
តារាង 5. ខេត្តដែលជាអាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត ..... 9
តារាង 6. ការចុះកម្មសិក្សា ឬហាត់ការ ..... 10
តារាង 7. តេស្តលទ្ធផល ..... 11
តារាង 8. កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារតាមជំនាញ ..... 11
តារាង 9. ចំណាត់ថ្នាក់បំណិនរបស់និស្សិតបញ្ចប់ការសិក្សា ..... 12
តារាង 10. ការផ្តល់ចំណាត់ថ្នាក់រវាងទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង ..... 13
តារាង 11. ប្រភេទការងាររបស់និស្សិត ..... 14
តារាង 12. ប្រភេទនៃកិច្ចសន្យាការងារ ..... 15
តារាង 13. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន ..... 15
តារាង 14. ស្ថានភាពការងារនៅតាមស្ថាប័ន ..... 16
តារាង 15. ចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា ..... 17
តារាង 16. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ ..... 18
តារាង 17. ភាពមានការងារធ្វើស្របតាមជំនាញ ..... 19
តារាង 18. ប្រាក់ចំណូលប្រចាំខែ ..... 21
តារាង 19. តេស្តលទ្ធផលទាក់ទងការផ្តល់ប្រាក់ឈ្នួលតាមភេទ និងធ្វើការត្រូវតាមជំនាញ ..... 22
តារាង 20. តេស្តលទ្ធផល ..... 23
តារាង 21. ការចំណាយពេលវេលាដើម្បីបង្កើតអាជីវកម្ម ..... 24
តារាង 22. ការបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញ ..... 25
តារាង 23. ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មស្របជំនាញផ្ទាល់ខ្លួន ..... 26
តារាង 24. តម្រូវការបំណិនជំនាញសម្រាប់ការងារ ..... 26
តារាង 25. តេស្តលទ្ធផលទាក់ទងជាមួយបំណិតលើជំនាញនីមួយៗ ..... 27
តារាង 26. កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ ..... 28
តារាង 27. ការជួយនិស្សិតដើម្បីទទួលបានការងារ ..... 29

**តារាង 28. តេស្តលទ្ធផល** ........................................ 29
**តារាង 29. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ** ........................................ 30
**តារាង 30. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត** ........................................ 30
**តារាង 31. ការសិក្សាជំនាញខ្លីៗ** ........................................ 30
**តារាង 32. ការចូលរួមសកម្មភាពសង្គម** ........................................ 31
**តារាង 33. តេស្តលទ្ធផល** ........................................ 31
**តារាង 32. ការវិភាគលទ្ធផលទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ** ........................................ 32

# ក្រាភិក

ក្រាភិក 1. បម្រែបម្រួលភាពមានការងារធ្វើរបស់និស្សិតនៅ៦ឆ្នាំចុងក្រោយ....7
ក្រាភិក 2. ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល....10
ក្រាភិក 3. កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា....11
ក្រាភិក 4. កម្រិតវាយតម្លៃនៃការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការអនុវត្ត....14
ក្រាភិក 5. ប្រភេទនៃកិច្ចសន្យាការងារ....15
ក្រាភិក 6. ភាគរយនិស្សិតទទួលបានការងារធ្វើតាមវិស័យ....16
ក្រាភិក 7. ភាគរយនៃនិស្សិតដែលទទួលបានការងារធ្វើនៅកន្លែងដែលបានចុះកម្មសិក្សា....17
ក្រាភិក 8. ភាគរយនៃនិស្សិតដែលត្រូវបានស្ថាប័នទទួលយកមកធ្វើការវិញកាលពីបានមកចុះកម្មសិក្សា....18
ក្រាភិក 9. ស្ថានភាពនៃឋានៈការងារ....19
ក្រាភិក 10. ភាគរយធ្វើការស្របជំនាញច្រើនជាង ៥០% និងតិចជាង៥០%....20
ក្រាភិក 11. ភាពមានការងារធ្វើមិនស្របតាមជំនាញ....21
ក្រាភិក 12. ករណីនានាដែលមិនទាន់មានការងារធ្វើ....22
ក្រាភិក 13. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា....23
ក្រាភិក 14. រយៈពេលទទួលបានការងារធ្វើស្របជំនាញ....24
ក្រាភិក 15. កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ....28

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ 1. គោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ....38
ឧបសម្ព័ន្ធ 2. លិខិតឧទ្ទេសនាម ....43
ឧបសម្ព័ន្ធ 3. កម្រងសំណួរស្រាវជ្រាវ ....45

# សេចក្តីសង្ខេបលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានមហាវិទ្យាល័យចំនួន៤ គឺមហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យរដ្ឋបាលសាធារណៈ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង និងមហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា។ ការសិក្សាពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សាត្រូវបានធ្វើឡើងចាប់ពីឆ្នាំ២០១៤មកនៅរៀងរាល់មុនពេលពិធីប្រគល់សញ្ញាបត្រ។ ការប្រៀបធៀបភាពមានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០១៧-២០១៨ និងនៅឆ្នាំសិក្សា២០២០-២០២១ ដើម្បីងាយស្រួលដឹងពីស្ថានភាពការងាររបស់និស្សិតនៅដំណាក់កាលមុនកូវីដ-១៩ និងដំណាក់កូវីដ-១៩។ ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានេះគឺសម្រាប់តែ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ដែលបាននិងកំពុងបណ្តុះបណ្តាលបរិញ្ញាបត្រឯកទេសចំនួន៥ ក្នុងនោះរួមមាន បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ បរិញ្ញាបត្រគណនេយ្យ បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ និងបរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១។

ការសិក្សាពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានេះ មានទំហំសំណាកដែលត្រូវបានប្រមូលចំនួន ៧៧៤នាក់ ស្មើនឹង ៨៣,៩៤% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាសរុប ៩២២នាក់នៅឆ្នាំសិក្សា ២០២០-២០២១។ លទ្ធផលជារួម និស្សិតមានការងារធ្វើមានចំនួន ៩៧,៧% និង ២,៣% ផ្សេងទៀតមិនទាន់មានការងារធ្វើ ដែលចំនួនការងារទាំងនោះមាន ៩២,៥% ជាកិច្ចសន្យាការងារពេញម៉ោង និង ៧,៥% ជាកិច្ចសន្យាការងារមិនពេញម៉ោង។ ជាការគួរឲ្យកត់សម្គាល់ ភាពមានការងារធ្វើស្របជំនាញលើស៥០% មានតែចំនួន៥៩,៩%។ និស្សិតចំនួន៨០,១% បានបម្រើការនៅក្នុងវិស័យឯកជន ចំនួន៨,៤% ក្នុងវិស័យសាធារណៈ និងចំនួន១១,៥% ក្នុងវិស័យផ្សេងទៀត។ ដោយឡែកចំពោះការចំណាយពេលរកការងារធ្វើ និស្សិតដែលមានការងារធ្វើស្រាប់មានចំនួន ៤១,០% រយៈពេលតិចជាង១ខែមានចំនួន១៨,៨% រយៈពេលចន្លោះ១ខែ ដល់៣ខែមានចំនួន១៩,២% និងរយៈពេលលើសពី៣ខែទៅមានចំនួន២១%។ ពាក់ព័ន្ធនឹងទីកន្លែងការងារ និស្សិតច្រើនលើសលប់បម្រើការនៅរាជធានីភ្នំពេញដែលមានចំនួន៨៣,០% បន្ទាប់មកនៅខេត្តកណ្តាលមានចំនួន៦,០% និងនៅតាមបណ្តាខេត្តផ្សេងៗមានចំនួនតែ១១%ប៉ុណ្ណោះ។ គួរកត់សម្គាល់ថា និស្សិតមានការងារធ្វើដែលទទួលបានប្រាក់ឈ្នួលចាប់ពី១០០០$ឡើងមានចំនួន២,៣% ហើយនិស្សិតទទួលបានប្រាក់ឈ្នួលនៅចន្លោះ២០០$-៦០០$ មានសរុបរហូតដល់ចំនួន ៨៦,០%។ និស្សិតអាចប្រើចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រក្នុងការបំពេញការងារមាន ៧១,៣% ខណៈមាន ១៦,៨% ប្រើចំណេះដឹងត្រូវខ្ពស់ជាងកម្រិតសញ្ញាបត្រដែលទទួលបានពីកម្មវិធីសិក្សា។ ជាចុងក្រោយនៃការសិក្សាបានរកឃើញថា កម្មវិធីសិក្សាជំនាញផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ដែលបាននិងកំពុងអនុវត្តក្នុងពេលបច្ចុប្បន្នបានឆ្លើយតបបានច្រើនចំណុចទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ រួមមាន ចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង។

# ផ្នែកទី១. សេចក្តីផ្តើម

## ១.១. សារៈសំខាន់នៃការសិក្សា

ការសិក្សាតាមដានលទ្ធផលរបស់និស្សិតបញ្ចប់ការសិក្សា គឺជាការសិក្សាស្រាវជ្រាវមួយដែលពាក់ព័ន្ធនឹងការតាមដាននិស្សិតដែលបានចុះឈ្មោះក្នុងវគ្គសិក្សាណាមួយរបស់គ្រឹះស្ថានសិក្សាមួយ ដោយគិតចាប់ពីពេលដែលនិស្សិតបានចុះឈ្មោះចូលរៀនក្នុងវគ្គសិក្សានោះ គឺពិនិត្យមើលការខិតខំរៀនក្នុងអំឡុងពេលសិក្សា និងអ្វីដែលពួកគេបានធ្វើជារៀងរាល់ឆ្នាំបន្ទាប់ពីពួកគេបានបញ្ចប់វគ្គសិក្សា សម្រាប់រយៈពេលមួយដែលពួកគេបានចូលរួម ឬបន្តការងារ ឬធ្វើការងារផ្ទាល់ខ្លួន។

ការសិក្សាតាមដានលទ្ធផលរបស់និស្សិតបញ្ចប់ការសិក្សា គឺជាវិធីសាស្ត្រមួយដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងស្ថាប័នភាគច្រើន ជាពិសេសនៅក្នុងស្ថាប័នអប់រំ ដើម្បីតាមដាន និងរក្សាកំណត់ត្រានិស្សិតរបស់ពួកគេនៅពេលដែលពួកគេបានបញ្ចប់ការសិក្សាពីស្ថាប័ននោះ។ វាជាការតាមដាននិស្សិតបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ឬវិទ្យាស្ថាន។ គោលបំណងគឺដើម្បីវាយតម្លៃពីភាពរីកចម្រើនរបស់និស្សិតរហូតដល់ពេលដែលពួកគាត់ទទួលបានការងារធ្វើ។ ការសិក្សានេះបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃការវិវត្តឧស្សាហកម្ម ដោយការរួមបញ្ចូលគ្នារវាងស្ថាប័នឧត្តមសិក្សានិងទីផ្សារការងារ។ អត្ថប្រយោជន៍នៃការសិក្សា គឺប្រើសម្រាប់ការគ្រប់គ្រង និងជាឧបករណ៍សម្រាប់ធ្វើផែនការ ការត្រួតពិនិត្យកម្មវិធីបណ្តុះបណ្តាល និងជាឧបករណ៍ដ៏សាមញ្ញដែលត្រូវបានបង្កើតឡើង ដើម្បីវាស់ស្ទង់នៃភាពជាប់ពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ ការសិក្សានេះបានផ្តល់ព័ត៌មានសម្រាប់ការផ្លាស់ប្តូរភាពខ្វះចន្លោះ និងការពិនិត្យឡើងវិញរបស់កម្មវិធីសិក្សាបណ្តុះបណ្តាល។

ការសិក្សាតាមដានលទ្ធផលអង្កេតរបស់និស្សិតបញ្ចប់ការសិក្សា អាចផ្តល់ឲ្យនូវព័ត៌មានសំខាន់ៗចំនួនបី៖ ទី១. ការផ្គូផ្គងជំនាញច្បាស់លាស់ ទី២. ការរួមបញ្ចូលគ្នានៃទិន្នន័យគោលដៅ និងទី៣. ប្រធានបទស្តីពីស្ថានភាពនិស្សិតបញ្ចប់ការសិក្សា។ ក្រៅពីភាពអាចវាស់វែងបានពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា និងទទួលបានមតិកែលម្អធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា លើសពីនេះលទ្ធផលនៃការសិក្សាបានបង្ហាញឲ្យឃើញទិដ្ឋភាពនៃការផ្គូផ្គងរវាងភាពពាក់ព័ន្ធរបស់ការងារចុះកម្មសិក្សា ឬការអនុវត្តផ្ទាល់នៅកន្លែងការងារ និងកម្រិតគុណវុឌ្ឍិមួយដែលត្រូវអាចវាស់វែងបាន។ ការសិក្សានេះអាចជួយឆ្លើយនូវសំណួរដូចជា៖

ក. តើមានអ្វីកើតឡើងចំពោះនិស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីបានចាកចេញពីគ្រឹះស្ថានឧត្តមសិក្សា?

ខ. តើចំណាយពេលប៉ុន្មានដែលអាចទទួលបានការងារធ្វើ និងទទួលបានប្រាក់ខែប៉ុន្មាន?

គ. តើអាចប្រើប្រាស់ជំនាញ និងសមត្ថភាពដែលទទួលបានពីការអប់រំ/ការបណ្តុះបណ្តាលដែរឬទេ?

ប្រសិនបើមិនបានប្រើប្រាស់ទេ តើបណ្តាលមកពីកត្តាអ្វីខ្លះ?

ឃ. តើជំនាញ និងសមត្ថភាពអ្វីខ្លះដែលត្រូវបានទាមទារដោយទីផ្សារការងារ?

លើសពីនេះ ការសិក្សាតាមដាននិស្សិតបញ្ចប់ការសិក្សាក្នុងរយៈពេលខ្លីខាងមុខ គឺជាការសិក្សាតាមដានសម្លឹងឆ្ពោះទៅអនាគត ដែលពាក់ព័ន្ធនឹងការរៀបចំផែនការ ដើម្បីតាមដានអ្នកសិក្សាចាប់ពីពេលដែលនសិស្សិតបានចុះឈ្មោះក្នុងវគ្គសិក្សា ឬកម្មវិធីសិក្សា ឬចាប់ពីពេលដែលពួកគេបានបញ្ចប់វគ្គសិក្សា ឬកម្មវិធីសិក្សាមួយ។ បន្ទាប់មកធ្វើការសិក្សាតាមដានអ្នកសិក្សាទាំងនោះក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ ដូច្នេះ យើងគួរស្នើឲ្យមានការ

កំណត់មុខវិជ្ជាដែលអាចបត់បែនបានជាថ្មី និងបង្កើតឲ្យមានការគាំទ្រយ៉ាងទូលំទូលាយ ហើយធ្វើការតាមដានអ្នកសិក្សាពីពេលដែលពួកគេបានចាប់ផ្តើមសិក្សាកម្មវិធីថ្មី រហូតដល់ពេលដែលពួកគេបានបញ្ចប់វគ្គសិក្សា ក្នុងគោលបំណងដើម្បីស្វែងយល់អំពីភាពរីកចំរើននៃជីវភាពរស់នៅរបស់ពួកគេនាពេលអនាគត។

## ១.២. វត្ថុបំណងនៃការសិក្សា

មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានបណ្តុះបណ្តាលនិស្សិតនៅលើជំនាញរបស់ខ្លួនបានជាច្រើនពាន់នាក់អស់ជាច្រើនឆ្នាំកន្លងមកហើយ និងបានធ្វើការសិក្សាស្រាវជ្រាវពីភាពមានការងារធ្វើរបស់និស្សិតបានចំនួន៨ដងរួចមកហើយគិតមកដល់ឆ្នាំ២០១៩ (មុនព្រឹត្តិការណ៍ជំងឺឆ្លងកូវីដ-១៩)។ នៅក្នុងដំណាក់កាលក្រោយពីជំងឺឆ្លងកូវីដ-១៩បានចុះថមថយ នេះជាឱកាសថ្មីមួយទៀតដែលទទួលបានបទពិសោធន៍ថ្មីៗពីគ្រឹះស្ថានឧត្តមសិក្សាស្តីពី «ភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា» បន្ទាប់ពីបានទៅចូលរួមសិក្ខាសាលាចំនួន២ដងរួចមក។ ការស្រាវជ្រាវនេះមានកម្មវត្ថុមួយចំនួនដូចខាងក្រោម៖

- ស្វែងរកចំនួនភាគរយភាពមានការងារធ្វើ
- រយៈពេលនៃការស្វែងរកការងារ
- កម្រិតប្រាក់ឈ្នួល
- កម្មវិធីសិក្សាឆ្លើយតបនឹងតម្រូវការការងាររបស់ទីផ្សារ
- សមត្ថភាពបង្កើតសហគ្រាសផ្ទាល់ខ្លួន
- និងចំណុចមួយចំនួនផ្សេងទៀតដែលជាការចំបាច់។

## ១.៣. ការប្រើប្រាស់លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា កន្លងមក

របាយការណ៍នេះ បានរៀបចំជាតារាងប្រៀបធៀបលទ្ធផលសិក្សាពីភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០១៧-២០១៨ និងភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២០-២០២១ ដែលជាការបញ្ចប់ការសិក្សាមួយដ៏លំបាករបស់និស្សិតនៅក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩ កំពុងរីករាលដាលខ្លាំងនៅឡើយ។ យោងគោលការណ៍ណែនាំលេខ ៦៥៥ ស.ភ.ន.វ.ស. ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស. (ឧបសម្ព័ន្ធ១) លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងព័ត៌មានត្រឡប់ពីនិស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២០-២០២១ និងកាលពីឆ្នាំសិក្សាកន្លងទៅយកមកពិនិត្យ និងស្រង់យកចំណុចគន្លឹះសំខាន់ៗចាំបាច់ ដែលត្រូវបានទាមទារពីការវិវត្តនៃទីផ្សារពលកម្មសម័យឌីជីថលទុក ជាមូលដ្ឋានសម្រាប់កែលម្អកម្មវិធីសិក្សានាពេលបច្ចុប្បន្ននិងទៅអនាគត ដើម្បីផ្តល់ដល់និស្សិតនូវអត្ថប្រយោជន៍យ៉ាងពេញលេញបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។

# ផ្នែកទី២. វិធីសាស្ត្រនៃការសិក្សា

## ២.១. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យសម្រាប់បង្កើតរបាយការណ៍ស្ដីពីស្ថានភាពនិស្សិតបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស. ត្រូវធ្វើឡើងដោយលិខិតឧទ្ទេសនាម លេខ៧២៨ ស.ភ.ន.វ.ស. ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ សម្រាប់កិច្ចដំណើរការប្រមូលទិន្នន័យ និងព័ត៌មានទាក់ទងនឹងការបញ្ចប់ការសិក្សារបស់និស្សិតនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រងក្នុងឆ្នាំសិក្សា ២០២០-២០២១។ ក្នុងលិខិតឧទ្ទេសនាមនេះ បានរៀបចំភារកិច្ចជា៣ផ្នែកធំៗរួមមាន៖ ទី១. គណៈកម្មការទទួលបន្ទុករួម ទី២. អនុគណៈកម្មការគាំទ្រ និងទី៣. អនុគណៈកម្មការបច្ចេកទេស។ គណៈកម្មការ និងអនុគណៈកម្មការតាមផ្នែកនីមួយៗបានបំពេញភារកិច្ចទៅតាមការកំណត់និងមានចែងនៅក្នុងលិខិតឧទ្ទេសនាម (ឧបសម្ព័ន្ធ២)។ អនុគណៈកម្មការគាំទ្រ បានប្រើប្រាស់កម្រងសំណួរតាមរយៈ Microsoft form បញ្ជូនទៅនិស្សិតនៅក្រុម Telegram តាមជំនាញនីមួយៗ ដោយទុករយៈពេល៩ថ្ងៃឲ្យនិស្សិតបំពេញ។ គ្រូទទួលបន្ទុកថ្នាក់ដើរតួនាទីសំខាន់ក្នុងការរំឭកនិស្សិតក្នុងក្រុមជាច្រើនដង។

## ២.២. ក្រុមគោលដៅផ្តល់សម្ភាសន៍ (អ្នកចូលរួមឆ្លើយសំណួរនៃការសិក្សា)

ក្រុមគោលដៅនៅក្នុងការសម្ភាសន៍នេះ គឺនិស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០២០-២០២១ រួមមាននិស្សិត បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ បរិញ្ញាបត្រគណនេយ្យ បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ និងគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ដែលជំនាញទាំងអស់នេះស្ថិតនៅក្រោមការបណ្ដុះបណ្ដាលរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង។ ទំហំសំណាកដែលប្រមូលបានមានចំនួន ៧៧៤នាក់ ស្មើនឹង៨៣,៩៤% ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាសរុបចំនួន៩២២នាក់។ ដូចនេះ ភាគរយនៃការឆ្លើយតបនេះមានកម្រិតជឿជាក់ខ្ពស់។

## ២.៣. ឧបករណ៍សម្រាប់ការសិក្សា និងការវិភាគទិន្នន័យ

ទិន្នន័យនិងព័ត៌មានដែលទាក់ទងនឹងនិស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ ត្រូវបានធ្វើឡើងតាមរយៈកម្រងសំណួរចំនួន៣៦សំណួរ។ កម្រងសំណួរបែកចេញជា៦ផ្នែក៖ ផ្នែកទី១. ព័ត៌មានផ្ទាល់ខ្លួនរបស់និស្សិត ផ្នែកទី២. ព័ត៌មានស្ដីពីការសិក្សា ផ្នែកទី៣. ព័ត៌មានស្ដីពីការបណ្ដុះបណ្ដាល ផ្នែកទី៤. ព័ត៌មានស្ដីពីស្ថានភាពមានការងារធ្វើ ផ្នែកទី៥. ព័ត៌មានស្ដីពីតម្រូវការមុខជំនាញ និងផ្នែកទី៦. សិក្សាលើព័ត៌មានត្រឡប់។ នៅក្នុងផ្នែកទី៦នេះ មានសំណួរបើកចំនួន៣សំណួរ សម្រាប់ស្វែងរកជំនាញផ្សេងៗទៀតដែលជាការវិវត្តនៃតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន (ឧបសម្ព័ន្ធ៣)។

ទិន្នន័យដែលទទួលបានពី Microsoft Form ត្រូវបានទាញជា Excel file រួចសម្អាតទិន្នន័យនិងកំណត់កូដឲ្យបានច្បាស់លាស់។ ជាចុងក្រោយ បញ្ចូល Excel file ទៅក្នុងកម្មវិធី SPSS ដើម្បីយកមកធ្វើការវិភាគដោយប្រើ Frequency, Descriptive, Cross table និង Independent Sample T- test ជាដើម ។

## ២.៤. វិសាលភាព និងដែនកំណត់នៃការសិក្សា

ការសិក្សាស្ដីពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២០-២០២១ គ្របដណ្ដប់ទៅលើនិស្សិតជំនាញគ្រប់គ្រងធុរកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និង

ជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង។

ដែនកំណត់នៃការសិក្សានេះ គឺចាប់ផ្តើមពីថ្ងៃទី២៣ ខែសីហា រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

## ២.៥. ក្រមសីលធម៌នៃការសិក្សា

ពាក្យពេចន៍ និងខ្លឹមសារដែលបានប្រើប្រាស់នៅក្នុងកម្រងសំណួរពុំមានចំណុច ឬផ្នែកណាមួយបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិបុគ្គលណាម្នាក់ទេ។ ការសិក្សានេះ រក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់និស្សិតដែលបានឆ្លើយតប។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ ត្រូវបានយកទៅប្រើប្រាស់តែក្នុងគោលបំណងអភិវឌ្ឍការបណ្តុះបណ្តាលរបស់កម្មវិធីអប់រំតែប៉ុណ្ណោះ។

## ផ្នែកទី៣. លទ្ធផលនៃការសិក្សា

ផ្នែកទី៣នេះនឹងពិនិត្យលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សា នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា ២០២០-២០២១ និងធ្វើការប្រៀបធៀបជាមួយឆ្នាំសិក្សា ២០១៧-២០១៨ (មុនការរីករាលដាលនៃជំងឺកូវីដ-១៩)។

**តារាង 1. ភាពមានការងារធ្វើរបស់និស្សិតឆ្នាំសិក្សា២០១៧-២០១៨ និងឆ្នាំសិក្សា២០២០-២០២១**

| ជំនាញ | ឆ្នាំសិក្សា ២០១៧-២០១៨ | | ឆ្នាំសិក្សា ២០២០-២០២១ | |
|---|---|---|---|---|
| | មុនបញ្ចប់ការសិក្សា | ក្រោយបញ្ចប់ការសិក្សា | មុនបញ្ចប់ការសិក្សា | ក្រោយបញ្ចប់ការសិក្សា |
| គ្រប់គ្រងធុរកិច្ច | 79.4% | 97.2% | 37.7% | 99.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | 76.2% | 95.2% | 35.3% | 95.3% |
| គណនេយ្យ | 74.6% | 94.4% | 48.3% | 98.9% |
| ធនាគារនិងហិរញ្ញវត្ថុ | 69.6% | 95.0% | 39.6% | 97.2% |
| គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | 77.1% | 100.0% | 56.5% | 95.7% |
| **សរុប** | **75.4%** | **96.4%** | **41.0%** | **97.7%** |

តារាងខាងលើនេះ បានបង្ហាញថាអត្រាភាពមានការងារធ្វើរបស់និស្សិតទាំង៥ជំនាញ មុនពេលមានជំងឺកូវីដ-១៩ មានការងារធ្វើចំនួន៧៥,៤% និងនៅក្នុងអំឡុងពេលជំងឺកូវីដ-១៩ បានថយចុះមកត្រឹម៤១,០%។ ផ្ទុយទៅវិញក្រោយបញ្ចប់ការសិក្សា អត្រាភាពមានការងារធ្វើរបស់និស្សិត មុនពេលមានជំងឺកូវីដ-១៩ មានចំនួន៩៦,៤% និងនៅក្នុងអំឡុងពេលជំងឺកូវីដ-១៩ បានកើនឡើងដល់៩៧,៧% ពោលគឺមានកំណើន១,៣%។

គួរកត់សម្គាល់ថា អត្រាការងារធ្វើទាបជាងគេបំផុត មុនបញ្ចប់ការសិក្សាក្នុងដំណាក់កាលកូវីដ-១៩ក្នុងចំណោមបរិញ្ញាបត្រទាំង៥គឺមានតែបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍ ដែលមានអត្រាចំនួន៣៥,៣%។

**តារាង 2. ភាពមានការងារធ្វើរបស់និស្សិតក្នុងអំឡុងពេល៦ឆ្នាំចុងក្រោយ (ឆ្នាំសិក្សាបញ្ចប់)**

| ជំនាញផ្នែកសេដ្ឋកិច្ច | 2014-2015 | 2015-2016 | 2016-2017 | 2017-2018 | 2018-2019 | 2020-2021 |
|---|---|---|---|---|---|---|
| គ្រប់គ្រងធុរកិច្ច | 92.5% | 96.9% | 96.8% | 97.2% | 97.3% | 99.0% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | 86.30% | 91.9% | 94.8% | 95.2% | 97.4% | 95.3% |
| គណនេយ្យ | 92.8% | 98.4% | 94.7% | 94.4% | 97.8% | 98.9% |
| ធនាគារនិងហិរញ្ញវត្ថុ | 95.4% | 96.8% | 95.4% | 95.0% | 98.3% | 97.2% |
| គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | 100% | 100% | 95.3% | 100% | 91.7% | 95.7% |
| អត្រាមធ្យមភាគភាពមានការងារធ្វើក្នុងឆ្នាំសិក្សានីមួយៗ | 93.4% | 96.8% | 95.4% | 96.4% | 96.5% | 97.2% |
| អត្រាមធ្យមភាគរួមនៃភាពមានការងារធ្វើក្នុងរយៈពេល៦ឆ្នាំចុងក្រោយ៖ 95.9% | | | | | | |

ប្រភព៖ របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស, ឆ្នាំ២០១៦ និងបន្តបន្ទាប់

លទ្ធផលនេះបង្ហាញថាកម្មវិធីបណ្តុះបណ្តាលជំនាញទាំង៥របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និង

គ្រប់គ្រង បានឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម និងការរីកចំរើនថ្មីនៃទីផ្សារការងារផងដែរ។

**ក្រាភិក 1. បម្រែបម្រួលភាពមានការងារធ្វើរបស់និស្សិតនៅ៦ឆ្នាំចុងក្រោយ**




ក្រាភិកខាងលើនេះបានបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០១៨-២០១៩ អត្រាភាគរយនៃអ្នកមានការងារធ្វើបានធ្លាក់ចុះ ស្ទើរគ្រប់ជំនាញទាំងអស់ អត្រាភាគរយនៃអ្នកមានការងារធ្វើខាងជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច បានធ្លាក់ចុះពី១០០%មក៩១.៧%។ ការធ្លាក់ចុះនេះ បណ្តាលមកពីផលប៉ះពាល់នៃការរីករាលនៃកូវីដ-១៩។

## ៣.១. ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួម

### ៣.១.១. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត

ក្នុងចំណោមនិស្សិតដែលបានឆ្លើយតបចំនួនសរុប៧៧៤នាក់ និស្សិតបុរសមានចំនួន២២៤នាក់ស្មើនឹង ២៨,៩% និងនារីមានចំនួន៥៥០នាក់ស្មើនឹង៧១,១%។ និស្សិតទាំងអស់នោះគឺជាអតីតសិស្សមកពីវិទ្យាល័យតាមបណ្តារាជធានី ខេត្តសរុបចំនួន២២ ដែលក្នុងនោះភាគច្រើនមករាជធានីភ្នំពេញចំនួន៣២,២% ខេត្តកណ្តាលចំនួន១៨,២% ខេត្តព្រៃវែងចំនួន៨,៧% ខេត្តតាកែវចំនួន៨,០% និងមានមកពីបណ្តាខេត្តផ្សេងៗទៀតចំនួន៣២,៩%។

**តារាង 3. អតីតសិស្សមកពីវិទ្យាល័យតាមរាជធានី និងខេត្ត**

| រាជធានី/ខេត្ត | ចំនួន | ភាគរយ |
|---|---|---|
| រាជធានីភ្នំពេញ | 249 | 32.2% |
| ខេត្តកណ្តាល | 141 | 18.2% |
| កំពង់ចាម | 45 | 5.8% |

| | | |
|---|---|---|
| បាត់ដំបង | 15 | 1.9% |
| ព្រៃវែង | 67 | 8.7% |
| សៀមរាប | 3 | 0.4% |
| តាកែវ | 62 | 8.0% |
| ខេត្តត្បូងឃ្មុំ | 24 | 3.1% |
| ខេត្តបន្ទាយមានជ័យ | 9 | 1.2% |
| ខេត្តកំពង់ស្ពឺ | 14 | 1.8% |
| ខេត្តកំពង់ធំ | 37 | 4.8% |
| ខេត្តកំពង់ឆ្នាំង | 15 | 1.9% |
| ខេត្តកំពត | 32 | 4.1% |
| ខេត្តស្វាយរៀង | 16 | 2.1% |
| ខេត្តពោធិ៍សាត់ | 14 | 1.8% |
| ខេត្តក្រចេះ | 5 | 0.6% |
| ខេត្តព្រះសីហនុ | 7 | 0.9% |
| ខេត្តព្រះវិហារ | 7 | 0.9% |
| ខេត្តរតនគិរី | 1 | 0.1% |
| ខេត្តកោះកុង | 7 | 0.9% |
| ខេត្តស្ទឹងត្រែង | 3 | 0.4% |
| ខេត្តមណ្ឌលគិរី | 1 | 0.1% |
| **សរុប** | **774** | **100%** |

### ៣.១.២. ចន្លោះអាយុរបស់និស្សិត

អាយុរបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ន ត្រូវបានកំណត់ជា៥ចន្លោះ ដែលក្នុងនោះមាន ទី១. អាយុក្រោម២២ឆ្នាំមានចំនួន១៦៧នាក់ ស្មើនឹង២១,៦% ទី២. អាយុចន្លោះ២២ឆ្នាំ ទៅ ២៦ឆ្នាំមានចំនួន៥៧៨នាក់ស្មើនឹង៧៤,៧% ទី៣. អាយុចន្លោះ២៦ឆ្នាំ ទៅ៣០ឆ្នាំមានចំនួន២៦នាក់ស្មើនឹង ៣,៤% ទី៤. អាយុចន្លោះ ៣០ឆ្នាំ ទៅ ៣៤ឆ្នាំមានចំនួន៣នាក់ស្មើនឹង០,៤% និងពុំមានអាយុលើសពី៣៤ឆ្នាំទេ។

**តារាង 4. ចន្លោះអាយុរបស់និស្សិត**

| អាយុ | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| អាយុតិចជាង 22 ឆ្នាំ | 167 | 21.6% | 21.6% |
| អាយុចន្លោះ 22-26 ឆ្នាំ | 578 | 74.7% | 96.3% |
| អាយុចន្លោះ 26-30 ឆ្នាំ | 26 | 3.4% | 99.6% |
| អាយុចន្លោះ 30-34 ឆ្នាំ | 3 | 0.4% | 100% |
| **សរុប** | **774** | **100%** | |

### ៣.១.៣. អាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត

តារាងខាងក្រោមបានបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សាច្រើនលើសលប់រហូតដល់ចំនួន៧៩,៦% រស់នៅរាជធានីភ្នំពេញ រីឯរស់នៅខេត្តកណ្តាល់មានចំនួន១០,៥%។ គួរកត់សម្គាល់ថាខេត្តដែលមាននិស្សិតបញ្ចប់ការសិក្សារស់នៅតិចជាងគេបំផុតគឺខេត្តឧត្តរមានជ័យ ដែលមានចំនួនតែ០,១%។

**តារាង 5. ខេត្តដែលជាអាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត**

| រាជធានី/ខេត្ត | ចំនួន | ភាគរយ |
|---|---|---|
| រាជធានីភ្នំពេញ | 616 | 79.6% |
| ខេត្តកណ្តាល | 81 | 10.5% |
| កំពង់ចាម | 3 | 0.4% |
| បាត់ដំបង | 6 | 0.8% |
| ព្រៃវែង | 13 | 1.7% |
| តាកែវ | 6 | 0.8% |
| ខេត្តត្បូងឃ្មុំ | 5 | 0.6% |
| ខេត្តបន្ទាយមានជ័យ | 1 | 0.1% |
| ខេត្តកំពង់ស្ពឺ | 5 | 0.6% |
| ខេត្តកំពង់ធំ | 4 | 0.5% |
| ខេត្តកំពង់ឆ្នាំង | 3 | 0.4% |
| ខេត្តកំពត | 11 | 1.4% |
| ខេត្តស្វាយរៀង | 4 | 0.5% |
| ខេត្តពោធិ៍សាត់ | 4 | 0.5% |
| ខេត្តព្រះសីហនុ | 4 | 0.5% |
| ខេត្តព្រះវិហារ | 2 | 0.3% |
| ខេត្តកោះកុង | 3 | 0.4% |
| ខេត្តស្ទឹងត្រែង | 2 | 0.3% |
| ខេត្តឧត្តរមានជ័យ | 1 | 0.1% |
| **សរុប** | **774** | **100%** |

## ៣.២. ព័ត៌មានពីការសិក្សា

និស្សិតដែលសិក្សាក្នុងមហាវិទ្យាល័យនេះ តម្រូវឲ្យសិក្សាជោគជ័យថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលគ្រប់គ្រងដោយដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងសិក្សាឆ្នាំទី២ ដល់ទី៤ ដែលគ្រប់គ្រងដោយការិយាល័យសិក្សា។

### ៣.២.១. ការចុះកម្មសិក្សា ឬហាត់ការ និងការទទួលបានប្រាក់ចំណូល

ដើម្បីបញ្ចប់ការសិក្សា និស្សិតឆ្នាំទី៤អាចមានជម្រើស២ ដែលក្នុងនោះជម្រើសទី១ និស្សិតអាចប្រឡងបញ្ចប់ដោយសិក្សាមុខវិជ្ជាចំនួន៣មុខនៅឆមាសទី២នៃឆ្នាំទី៤ និងជម្រើសទី២ និស្សិតពូកែចំនួន១៥%នៃថ្នាក់នីមួយៗអាចសរសេរសារណាបញ្ចប់ការសិក្សា ឬចុះកម្មសិក្សានិងសរសេររបាយការណ៍កម្មសិក្សា។ លើសពីនេះ និស្សិតដែលមិនមែនឆ្នាំទី៤ ក៏អាចចុះហាត់ការនៅតាមស្ថាប័ន ឬក្រុមហ៊ុននានា ដើម្បីទទួលបានបទពិសោធន៍ការងារនៅ

មុនបញ្ចប់ការសិក្សារបស់ពួកគេដែរ។

តារាងខាងក្រោមនេះបង្ហាញចំនួននិស្សិតដែលបានចុះកម្មសិក្សា/ហាត់ការ និងទទួលបានប្រាក់ចំណូលខ្លះ។

### ៣.២.១.១. ការចុះកម្មសិក្សា ឬហាត់ការ

តារាង 6. ការចុះកម្មសិក្សា ឬហាត់ការ

| ជំនាញ | | ចុះកម្មសិក្សា/ហាត់ការ | | សរុប |
|---|---|---|---|---|
| | | មាន | មិនមាន | |
| គ្រប់គ្រងធុរកិច្ច | ចំនួន | 83 | 109 | 192 |
| | % | 43.2% | 56.8% | 100% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ចំនួន | 44 | 84 | 128 |
| | % | 34.4% | 65.6% | 100% |
| គណនេយ្យ | ចំនួន | 78 | 105 | 183 |
| | % | 42.6% | 57.4% | 100% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 110 | 138 | 248 |
| | % | 44.4% | 55.6% | 100% |
| គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច | ចំនួន | 12 | 11 | 23 |
| | % | 52.2% | 47.8% | 100% |
| **សរុប** | **ចំនួន** | 327 | 447 | 774 |
| | **%** | 42.2% | 57.8% | 100% |

តារាងខាងលើបានបង្ហាញថា និស្សិតចំនួន៤២,២% បានចុះកម្មសិក្សា/ហាត់ការ ក្នុងចំណោមនិស្សិតសរុបចំនួន៧៧៤នាក់។ គួរកត់សម្គាល់ថា និស្សិតដែលបានចុះកម្មសិក្សា/ហាត់ការច្រើនជាងគេគឺនិស្សិតសិក្សាជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ដែលមានចំនួន៥២,២%នៃនិស្សិតសរុបក្នុងជំនាញនេះមាន២៣នាក់ ហើយនិស្សិតដែលចុះកម្មសិក្សាតិចជាងគេគឺនិស្សិតសិក្សាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ដែលមានចំនួន៣៤,៤%នៃនិស្សិតសរុប១២៨នាក់។

### ៣.២.១.២. ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល

ក្រាភិក 2. ការចុះកម្មសិក្សា/ហាត់ការ និងការទទួលបានចំណូល



ក្រាភិកខាងលើបានបង្ហាញ ក្នុងចំណោមនិស្សិតដែលបានចុះកម្មសិក្សាឬហាត់ការ ចំនួន៣២៧នាក់ និស្សិតដែលទទួលបានប្រាក់ចំណូល មានចំនួនសរុប៨៩,៩% ហើយមាននិស្សិតចំនួន១០,១%ប៉ុណ្ណោះ ដែលមិនបានទទួលប្រាប់ចំណូល។ និស្សិតដែលបានទទួលបានប្រាក់ចំណូលចន្លោះ១០០-២០០$ មានចំនួន៤៧,១%។

### ៣.២.២. សេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាដែលអាចឆ្លើយតបទីផ្សារការងារ

កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា ដែលគិតថាអាចបំពេញការងារឆ្លើយតបតម្រូវការទីផ្សារបង្ហាញក្នុងតារាងខាងក្រោម៖

**ក្រាភិក 3. កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សា**




គួរកត់សម្គាល់ថា ក្នុងចំណោមនិស្សិតឆ្លើយតប៧៧៤នាក់ និស្សិតដែលពេញចិត្តកម្មវិធីចាប់ពីបង្គួរទៅមានសរុបចំនួន៩៦,០% ហើយនិស្សិតពេញចិត្តកម្មវិធីតិចតួចមានតែ០,៤% ប៉ុណ្ណោះ។

**តារាង 7. តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| Curriculum Satisfaction | 774 | 3.59 | 0.687 | 145.59 | 0.000 | 3.55 | 3.64 |

***: Significant risk at 1%, **: Significant risk at 5%, *: Significant risk at 10%

បើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥% និស្សិតលើសពីចំនួន ៥០,០% បាន *ពេញចិត្តខ្លាំង* ចំពោះកម្មវិធីសិក្សាដែលបានបណ្តុះបណ្តាលនៅមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង។

***តារាង 8.* កម្រិតសេចក្តីពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារ *តាមជំនាញ***

| តារាងពេញចិត្តដោយឡែកចំពោះកម្មវិធីសិក្សាតាមតម្រូវការទីផ្សារ | | | | | | | |
|---|---|---|---|---|---|---|---|
| | | ពេញចិត្តតិចតួច | ពេញចិត្តមធ្យម | ពេញចិត្តបង្គួរ | ពេញចិត្តខ្លាំង | ពេញចិត្តខ្លាំងណាស់ | សរុប |
| **គ្រប់គ្រងធុរកិច្ច** | ចំនួន | 2 | 14 | 78 | 84 | 14 | 192 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | % | 1.0% | 7.3% | 40.6% | 43.8% | 7.3% | 100% |
| **សេដ្ឋកិច្ចអភិវឌ្ឍន៍** | ចំនួន | 1 | 4 | 44 | 65 | 14 | 128 |
| | % | 0.8% | 3.1% | 34.4% | 50.8% | 10.9% | 100% |
| **គណនេយ្យ** | ចំនួន | 0 | 6 | 74 | 91 | 12 | 183 |
| | % | 0.0% | 3.3% | 40.4% | 49.7% | 6.6% | 100% |
| **ធនាគារ និងហិរញ្ញវត្ថុ** | ចំនួន | 0 | 2 | 95 | 139 | 12 | 248 |
| | % | 0.0% | 0.8% | 38.3% | 56.0% | 4.8% | 100% |
| **គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច** | ចំនួន | 0 | 2 | 10 | 11 | 0 | 23 |
| | % | 0.0% | 8.7% | 43.5% | 47.8% | 0.0% | 100% |
| **សរុប** | **ចំនួន** | **3** | **28** | **301** | **390** | **52** | **774** |
| | **%** | **0.4%** | **3.6%** | **38.9%** | **50.4%** | **6.7%** | **100%** |

តារាងខាងលើបង្ហាញថា សេចក្តីពេញចិត្តរបស់និស្សិតបញ្ចប់ការសិក្សាតាមជំនាញនីមួយៗ ចំពោះកម្មវិធីសិក្សាចាប់ពីកម្រិតបង្គួរឡើងមានចំនួនលើសពី៩៦%។ គួរឲ្យកត់សម្គាល់ និស្សិតជំនាញធនាគារនិងហិរញ្ញវត្ថុមានសេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សា ចាប់ពីកម្រិតបង្គួរឡើងមានចំនួន៩៩,១%។

## ៣.៣. ព័ត៌មានពីកម្មវិធីសិក្សា

កម្មវិធីសិក្សា/ជំនាញទាំង៥ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានធ្វើការកែលម្អកម្មវិធីសិក្សាចុងក្រោយនៅឆ្នាំ២០១៨ ឲ្យស្របទៅតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិដែលបានកំណត់ និងបានដាក់ឲ្យអនុវត្តរហូតមកដល់បច្ចុប្បន្ន។ កន្លងមក នៅឆ្នាំសិក្សា ២០២០-២០២១ គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាដែលហៅកាត់ថា «គ.ទ.ក» បានចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងទទួលបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ក្នុងនោះកម្មវិធីសិក្សានៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង ក៏បានផ្តល់អានុសាសន៍កែលម្អឲ្យកាន់តែប្រសើរបានម្តងរួចមកហើយ។

ខាងក្រោមនេះជាតារាងលទ្ធផលថ្មីមួយទៀត ដែលបានធ្វើការស្រាវជ្រាវជាបន្តទៀតលើនិស្សិតបញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០២០-២០២១ ចំនួន៥ជំនាញ ខាងនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង កាលពីថ្ងៃទី២៣ ដល់ថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២២ កន្លងទៅនេះ។ លទ្ធផលចំណាត់ថ្នាក់បំណិនដែលនិស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីបានរៀនចប់ក្នុងរយៈពេល៤ឆ្នាំត្រូវបានបង្ហាញលើតារាងខាងក្រោមនេះ

**តារាង ៩. ចំណាត់ថ្នាក់បំណិនរបស់និស្សិតបញ្ចប់ការសិក្សា**

| លរ | បរិយាយ | | តិចតួច | មធ្យម | ច្រើនបង្គួរ | ច្រើន | ច្រើនណាស់ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការច្នៃប្រឌិត | ចំនួន | 14 | 38 | 392 | 305 | 25 | 774 |
| | | % | 1.8% | 4.9% | 50.6% | 39.4% | 3.2% | 100% |
| ២ | ការងារជាក្រុម | ចំនួន | 3 | 26 | 248 | 430 | 67 | 774 |
| | | % | 0.4% | 3.4% | 32.0% | 55.6% | 8.7% | 100% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ការគិតពិចារណា | ចំនួន | 2 | 15 | 272 | 438 | 47 | 774 |
| | | % | 0.3% | 1.9% | 35.1% | 56.6% | 6.1% | 100% |
| ៤ | ការដោះស្រាយបញ្ហា | ចំនួន | 1 | 36 | 331 | 351 | 55 | 774 |
| | | % | 0.1% | 4.7% | 42.8% | 45.3% | 7.1% | 100% |
| ៥ | សហគ្រិនភាព | ចំនួន | 24 | 95 | 465 | 174 | 16 | 774 |
| | | % | 3.1% | 12.3% | 60.1% | 22.5% | 2.1% | 100% |
| ៦ | ភាពជាអ្នកដឹកនាំ | ចំនួន | 9 | 72 | 380 | 279 | 34 | 774 |
| | | % | 1.2% | 9.3% | 49.1% | 36.0% | 4.4% | 100% |
| ៧ | ការសម្រេចចិត្ត | ចំនួន | 6 | 31 | 298 | 394 | 45 | 774 |
| | | % | 0.8% | 4.0% | 38.5% | 50.9% | 5.8% | 100% |
| ៨ | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន | ចំនួន | 12 | 71 | 378 | 269 | 44 | 774 |
| | | % | 1.6% | 9.2% | 48.8% | 34.8% | 5.7% | 100% |
| ៩ | ការប្រាស្រ័យទាក់ទងគ្នា | ចំនួន | 4 | 19 | 229 | 410 | 112 | 774 |
| | | % | 0.5% | 2.5% | 29.6% | 53.0% | 14.5% | 100% |
| ១០ | ភាសាអង់គ្លេស | ចំនួន | 10 | 42 | 423 | 273 | 26 | 774 |
| | | % | 1.3% | 5.4% | 54.7% | 35.3% | 3.4% | 100% |

តារាងខាងលើនេះបង្ហាញថា ចំណុចនានានៃបំណិនត្រូវបានបង្ហាញពីកម្រិតនៃការផ្សារភ្ជាប់ទំនាក់ទំនងរវាងទ្រឹស្តីដែលបានសិក្សានិងការអនុវត្តក្នុងការងារជាក់ស្តែងដែលនិស្សិតបានជួបប្រទះ។ គួរឲ្យកត់សម្គាល់ ក្នុងចំណោមបំណិននានាដែលចាប់ពីកម្រិតច្រើនបង្គួរឡើង បំណិនដែលមានកម្រិតខ្ពស់ជាងគេគឺផ្នែកការគិតពិចារណា មានចំនួន៩៩,៨០% ដោយឡែកបំណិនដែលមានកម្រិតទាបជាងគេ គឺផ្នែកសហគ្រិនភាព មាន៨៤,៧០%។

**តារាង 10. ការផ្តល់ចំណាត់ថ្នាក់រវាងទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង**

| **តារាងបង្ហាញការវាយតម្លៃការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការងារអនុវត្ត** | | | |
|---|---|---|---|
| **កម្រិតវាយតម្លៃ** | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
| តិចតួច | 12 | 1.6% | 1.6% |
| មធ្យម | 47 | 6.1% | 7.6% |
| ច្រើនបង្គួរ | 377 | 48.7% | 56.3% |
| ច្រើន | 313 | 40.4% | 96.8% |
| ច្រើនណាស់ | 25 | 3.2% | 100% |
| **សរុប** | **774** | **100%** | |

នៅលើតារាងខាងលើបង្ហាញថា និស្សិតចំនួន៩២,៤% នៃនិស្សិតសរុប៧៧៤នាក់ គិតថាទ្រឹស្តីបានផ្សារភ្ជាប់នឹងការអនុវត្តការងារជាក់ស្តែងបានចាប់កម្រិតច្រើនបង្គួរឡើង។ ដោយឡែក និស្សិតចំនួន ៧,៦% គិតថាទ្រឹស្តីបានផ្សារភ្ជាប់នឹងការអនុវត្តការងារជាក់ស្តែងបានកម្រិតក្រោមមធ្យម។

**ក្រាភិក 4. កម្រិតវាយតម្លៃនៃការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការអនុវត្ត**




## ៣.៤. ព័ត៌មានពីស្ថានភាពការងារ

និស្សិតដែលបានចាប់ផ្តើមចូលសិក្សានៅសាកលវិទ្យាល័យអាចមានមួយចំនួនស្វែងរកការងារធ្វើ និងមួយចំនួនទៀតមិនស្វែងរកការងារធ្វើគឺដោយសារមានកត្តាផ្សេងៗដូចជា ចង់បានបទពិសោធន៍ការងារថ្មី កត្តាហិរញ្ញវត្ថុ ស្វែងរកចំណូលសម្រាប់បំពេញតម្រូវការនៃការសិក្សា ឬកត្តាជីវភាព ចូលប្រឡូកក្នុងកិច្ចការសង្គមផ្សេងៗ។ល។ ទំនងដោយសារហេតុផលទាំងនេះហើយ បានជាមាននិស្សិតខ្លះមានការងារធ្វើតាំងតែពីពួកគាត់នៅជានិស្សិតកំពុងសិក្សានៅឡើយ ហើយក៏អាចមាននិស្សិតមួយចំនួនអាចបង្កើតសហគ្រាសខ្នាតតូចផ្ទាល់ខ្លួនបានផងដែរ។ ខាងក្រោមនេះជាស្ថានភាពមានការងារធ្វើរបស់និស្សិត ដែលបានបញ្ចប់ការសិក្សានៅក្នុងកំលុងពេលដែលមានជំងឺឆ្លងកូវីដ-19 នៃឆ្នាំសិក្សា២០២០-២០២១។

### ៣.៤.១. ប្រភេទការងាររបស់និស្សិត

**តារាង 11. ប្រភេទការងាររបស់និស្សិត**

| ប្រភេទការងារ | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| មានការងារធ្វើ | 556 | 71.8% | 71.8% |
| មានអាជីវកម្មផ្ទាល់ខ្លួន | 66 | 8.5% | 80.4% |
| នៅបន្តការសិក្សា | 11 | 1.4% | 81.8% |
| មានការងារធ្វើ និងមានអាជីវកម្មផ្ទាល់ខ្លួន | 31 | 4.0% | 85.8% |
| មានការងារធ្វើ និងបន្តការសិក្សា | 65 | 8.4% | 94.2% |
| ជាព្រះសង្ឃ | 1 | 0.1% | 94.3% |
| គ្មានការងារធ្វើ | 18 | 2.3% | 96.6% |
| ផ្សេងទៀត | 26 | 3.4% | 100% |
| **សរុប** | **774** | **100%** | |

តារាងខាងលើ កត់សម្គាល់ឃើញថា និស្សិតបញ្ចប់ការសិក្សាដែលមានអាជីវកម្មផ្ទាល់ខ្លួនមានចំនួន៨,៥% នៃចំនួននិស្សិតសរុប៧៧៤នាក់។

### ៣.៤.២. ប្រភេទនៃកិច្ចសន្យាការងារ

ការងារទាំងនោះអាចមានជាប្រភេទការងារពេញម៉ោង និងការងារមិនពេញម៉ោងគឺអាស្រ័យលើកិច្ចសន្យាការងារដែលនិយោជក់និងនិយោជិតមានការព្រងពព្រៀងគ្នាទៅតាមស្ថានភាពការងារឬលក្ខខណ្ឌការងារ។ ខាងក្រោមនេះជាតារាងប្រភេទនៃកិច្ចសន្យាការងារដែលនិស្សិតបញ្ចប់ការសិក្សាទទួលបានមាននៅខាងក្រោមនេះ

**តារាង 12. ប្រភេទនៃកិច្ចសន្យាការងារ**

| ប្រភេទនៃកិច្ចសន្យាការងារ | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| ការងារពេញម៉ោង | 716 | 92.5% | 92.5% |
| ការងារមិនពេញម៉ោង | 58 | 7.5% | 100% |
| **សរុប** | **774** | **100%** | |

តារាងខាងលើបានបង្ហាញថា និស្សិតបញ្ចប់ការសិក្សាដែលមានការងារធ្វើពេញម៉ោងមានចំនួន៩២,៥% នៃនិស្សិតសរុបចំនួន៧៧៤នាក់។

**ក្រាភិក 5. ប្រភេទនៃកិច្ចសន្យាការងារ**




### ៣.៤.៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន

និស្សិតមួយចំនួនទទួលបានឱកាស និងមានលទ្ធភាពអាចបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនបានជាបន្តបន្ទាប់ ក្រោយពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។

**តារាង 13. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន**

<table>
<tr><th colspan="7">តារាងការបង្កើតសហគ្រាសផ្ទាល់ខ្លួនបន្ទាប់ពីបញ្ចប់ការសិក្សា</th></tr>
<tr><th colspan="2" rowspan="2"></th><th colspan="4">ទំហំសហគ្រាស/អាជីវកម្មផ្ទាល់ខ្លួន</th><th rowspan="2">សរុប</th></tr>
<tr><th>សហគ្រាស ខ្នាតតូច</th><th>សហគ្រាស ខ្នាតតូច</th><th>សហគ្រាស ខ្នាតតូច</th><th>អាជីវកម្មផ្សេងៗ</th></tr>
<tr><td rowspan="2">សហគ្រាសផ្ទាល់ខ្លួន</td><td>ចំនួន</td><td>38</td><td>7</td><td>1</td><td>20</td><td>66</td></tr>
<tr><td>%</td><td>57.6%</td><td>10.6%</td><td>1.5%</td><td>30.3%</td><td>100%</td></tr>
</table>

| | | | | | | |
|---|---|---|---|---|---|---|
| **សរុប** | ចំនួន | 38 | 7 | 1 | 20 | 66 |
| | % | 57.6% | 10.6% | 1.5% | 30.3% | 100% |

នៅលើតារាងបង្ហាញឲ្យឃើញថា ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាដែលមានបង្កើតសហគ្រាស/អាជីវកម្មផ្ទាល់ខ្លួនចំនួន៥៧,៦% នៃនិស្សិតចំនួន៦៦នាក់។

### ៣.៤.៤. ប្រភេទនៃស្ថាប័នអាជីវកម្មដែលនិស្សិតបញ្ចប់ការសិក្សាបាន និងកំពុងបំពេញការងារ

និស្សិតបញ្ចប់ការសិក្សាបានទៅស្វែងរកការងារធ្វើនៅតាមស្ថាប័ននានា គ្រឹះស្ថានអាជីវកម្មផ្សេងៗទាំងនៅក្នុងស្ថាប័នរដ្ឋ ក៏ដូចជានៅក្នុងក្រុមហ៊ុនឯកជនព្រមទាំងនៅតាមបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការដែលមានទីតាំងទាំងនៅក្នុងស្រុកនិងនៅឯបរទេសដែរ។

**តារាង 14. ស្ថានភាពការងារនៅតាមស្ថាប័ន**

| តារាងស្ថានភាពការងារនៅតាមស្ថាប័ននានា | | | |
|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
| ស្ថាប័នរដ្ឋ | 63 | 8.4% | 8.4% |
| ក្រុមហ៊ុនឯកជន | 602 | 80.1% | 88.4% |
| អង្គការជាតិ | 3 | 0.4% | 88.8% |
| អង្គការអន្តរជាតិ | 4 | 0.5% | 89.4% |
| ភ្នាក់ងារសហប្រតិបត្តិការ | 5 | 0.7% | 90.0% |
| ផ្សេងៗ | 75 | 10.0% | 100% |
| **សរុប** | **752** | **100%** | |

តារាងខាងលើបានបង្ហាញថា និស្សិតបញ្ចប់ការសិក្សាបានបម្រើការងារនៅក្នុងវិស័យឯកជនមានចំនួន៨០,១% នៃនិស្សិតសរុបចំនួន៧៥២នាក់។

វិស័យឯកជនដើរតួនាទីសំខាន់ក្នុងការស្រូបយកកម្លាំងពលកម្ម បន្ទាប់ពីនិស្សិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំនានាជាពិសេសជំនាញក្នុងវិស័យសេដ្ឋកិច្ច។

**ក្រាភិក 6. ភាគរយនិស្សិតទទួលបានការងារធ្វើតាមវិស័យ**



### ៣.៤.៥. ការទទួលបានការងារធ្វើនៅកន្លែងការចុះកម្មសិក្សា

និស្សិតបន្ទាប់ពីបានបញ្ចប់ការសិក្សាភ្លាមបានស្វែងរកការងារធ្វើនៅតាមស្ថាប័ននានាទាំងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន និងនៅតាមអង្គការនានាអាស្រ័យតាមលទ្ធភាព សមត្ថភាពដែលនិស្សិតបានសិក្សាពីសាកលវិទ្យាល័យ ឬទៅតាមចំណង់ចំណូលចិត្ត ហើយក៏មាននិស្សិតខ្លះអាចទទួលបានការងារធ្វើនៅនឹងស្ថាប័ន ឬក្រុមហ៊ុនដែលធ្លាប់បានចុះកម្មសិក្សាផងដែរ។

**តារាង 15. ចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា**

| តារាងបង្ហាញចំនួននិស្សិតទទួលបានការងារធ្វើនៅកន្លែងដែលធ្លាប់បានចុះទៅធ្វើកម្មសិក្សា | | | |
|---|---|---|---|
| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
| បានការងារធ្វើនៅកន្លែងចុះធ្វើកម្មសិក្សា | 222 | 71.2% | 71.2% |
| មិនបានការងារធ្វើនៅកន្លែងចុះធ្វើកម្មសិក្សា | 90 | 28.8% | 100.0% |
| **សរុប** | **312** | **100.0%** | |

តារាងខាងលើបានបង្ហាញថា ក្នុងចំណោមនិស្សិតដែលបានចុះកម្មសិក្សាចំនួន៣១២នាក់ មាននិស្សិតដែលបានធ្វើនៅកន្លែងចុះកម្មសិក្សាមានចំនួន៧១.២%។

ក្នុងរយៈពេលនៃការបំពេញការងារជាអ្នកហាត់ការនិស្សិតម្នាក់ៗបានបញ្ចេញអស់ពីសមត្ថភាព ដើម្បីធ្វើកិច្ចការទាំងនោះឲ្យបានជោគជ័យ។ ឆ្លងតាមរយៈលទ្ធផលការងារ និស្សិតហាត់ការអាចដឹង ឬអាចទទួលបានការងារធ្វើបន្ទាប់ពីថេរៈវេលានៃការចុះកម្មសិក្សាត្រូវបានបញ្ចប់។

ខាងក្រោមនេះជាក្រាភិកបង្ហាញពីលទ្ធភាពទទួលបានការងារធ្វើនៅកន្លែងដែលបានចុះកម្មសិក្សា។

**ក្រាភិក 7. ភាគរយនៃនិស្សិតដែលទទួលបានការងារធ្វើនៅកន្លែងដែលបានចុះកម្មសិក្សា**



**ក្រាភិក ៨. ភាគរយនៃនិស្សិតដែលត្រូវបានស្ថាប័នទទួលយកមកធ្វើការវិញកាលពីបានមកចុះកម្មសិក្សា**




ក្រាភិកខាងលើបានបង្ហាញថា និស្សិតភាគនច្រើនលើសលប់ដែលបានធ្វើការនៅកន្លែងដែលបានចុះកម្មសិក្សា គឺក្រុមហ៊ុនឯកជន ដែលមានរហូតដល់៨២.២៩%។

### ៣.៤.៦. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ

និស្សិតដែលបានបញ្ចប់ការសិក្សាបានទៅបំពេញការងារតាមជំនាញរៀងៗខ្លួន និងនៅតាមស្ថាប័ននានាទូទាំងរាជធានី និងបណ្តាខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ តទៅនេះយើងនឹងដឹងស្ថានភាពទីតាំងការងាររបស់និស្សិតបញ្ចប់ការសិក្សា។ ជាលទ្ធផលបញ្ជាក់ថា ភាគច្រើនលើសលប់ និស្សិតបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅក្នុងទូទាំងរាជធានីភ្នំពេញជាង ៨៣% មានការងារធ្វើនៅខេត្តកណ្តាលជិត ៦% ធ្វើការនៅខេត្តព្រៃវែងមានប្រមាណ ១,៣% ធ្វើការនៅខេត្តកំពតមានប្រមាណ ១,២% ធ្វើការនៅខេត្តតាកែវ ១,០%។ ចំណែកឯនិស្សិតដែលមានការងារធ្វើនៅតាមបណ្តាខេត្តផ្សេងៗទៀតដែលខេត្តនីមួយៗមានចំនួនតិចជាង ១,០%។

**តារាង 16. ទីកន្លែងដែលនិស្សិតទទួលបានការងារធ្វើ**

| រាជធានី/ខេត្ត | ចំនួន | ភាគរយ |
|---|---|---|
| រាជធានីភ្នំពេញ | 643 | 83.1% |
| ខេត្តកណ្តាល | 51 | 6.6% |
| ខេត្តកំពង់ចាម | 5 | 0.6% |
| ខេត្តបាត់ដំបង | 7 | 0.9% |
| ខេត្តព្រៃវែង | 10 | 1.3% |
| ខេត្តតាកែវ | 8 | 1.0% |
| ខេត្តត្បូងឃ្មុំ | 6 | 0.8% |
| ខេត្តបន្ទាយមានជ័យ | 1 | 0.1% |
| ខេត្តកំពង់ស្ពឺ | 6 | 0.8% |
| ខេត្តកំពង់ធំ | 4 | 0.5% |
| ខេត្តកំពង់ឆ្នាំង | 4 | 0.5% |
| ខេត្តកំពត | 9 | 1.2% |

| | | |
|---|---|---|
| ខេត្តស្វាយរៀង | 3 | 0.4% |
| ខេត្តពោធិ៍សាត់ | 3 | 0.4% |
| ខេត្តព្រះសីហនុ | 4 | 0.5% |
| ខេត្តព្រះវិហារ | 3 | 0.4% |
| ខេត្តកោះកុង | 3 | 0.4% |
| ខេត្តស្ទឹងត្រែង | 3 | 0.4% |
| ខេត្តឧត្តរមានជ័យ | 1 | 0.1% |
| **សរុប** | **774** | **100%** |

### ៣.៤.៧. ឋានៈការងារនៅក្នុងស្ថាប័ន

ការចាប់ផ្តើមការងារដំបូង អង្គភាពអាជីវកម្ម ឬអង្គភាពរបស់រដ្ឋតែងតែបង្ហាញឋានៈតួនាទីទៅកាន់បុគ្គលិកថ្មីដើម្បីទុកជាព័ត៌មានលើកទឹកចិត្ត។ ខាងក្រោមនេះជាស្ថានភាពនៃឋានៈការងារដែលនិស្សិតបញ្ចប់ការសិក្សាបានទទួលនៅកន្លែងការងារ។

**ក្រាភិក 9. ស្ថានភាពនៃឋានៈការងារ**




នៅលើក្រាភិកបង្ហាញកម្រិតឋានានុក្រមការងាររបស់និស្សិតបញ្ចប់ការសិក្សាបន្ទាប់ពីទទួលបានការងារធ្វើនៅក្នុងស្ថាប័នរដ្ឋ ឬអង្គភាពអាជីវកម្ម។ ឋានៈឬតួនាទីទី១. ជាបុគ្គលិកទូទៅមាន ៨១,៨% ទី២. មានតួនាទីជាអ្នកបច្ចេកទេសមានចំនួន ៧,២% ទី៣. មានតួនាទីជាអ្នកគ្រប់គ្រងកម្រិតកណ្តាលមានចំនួន ៩,៦% និងទី៤. មានតួនាទីជាអ្នកគ្រប់គ្រងកម្រិតខ្ពស់មានចំនួន ១,៥%។

### ៣.៤.៨. ភាពមានការងារធ្វើស្របជំនាញច្រើនជាង ឬតិចជាង៥0% នៃកម្មវិធីសិក្សា

#### ៣.៤.៨.១. ភាពមានការងារធ្វើស្របជំនាញ

**តារាង 17. ភាពមានការងារធ្វើស្របតាមជំនាញ**

| ភាពមានការងារធ្វើស្របតាមជំនាញ | | | | |
|---|---|---|---|---|
| | | **ធ្វើការស្របជំនាញលើស 50%** | **ធ្វើការស្របជំនាញតិចជាង 50%** | **សរុប** |
| គ្រប់គ្រងធុរកិច្ច | ចំនួន | 119 | 67 | 186 |
| | % | 64.0% | 36.0% | 100% |
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ចំនួន | 61 | 56 | 117 |
| | % | 52.1% | 47.9% | 100% |

| | | | | |
|---|---|---|---|---|
| គណនេយ្យ | ចំនួន | 107 | 72 | 179 |
| | % | 59.8% | 40.2% | 100% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 153 | 85 | 238 |
| | % | 64.3% | 35.7% | 100% |
| គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច | ចំនួន | 5 | 18 | 23 |
| | % | 21.7% | 78.3% | 100% |
| **សរុប** | **ចំនួន** | **445** | **298** | **743** |
| | **%** | **59.9%** | **40.1%** | **100%** |

តារាងខាងលើបានបង្ហាញថា និស្សិត ៧៤៣នាក់ ក្នុងនោះមាន ៤៤៥នាក់ ស្មើនឹង ៥៩,៩% មានការងារធ្វើស្របជំនាញច្រើនជាង៥០% នៃកម្មវិធីសិក្សាដែលបានរៀនចប់ពីសាកលវិទ្យាល័យ និងចំនួន ២៩៨នាក់ស្មើនឹង ៤០,១% មានការងារធ្វើស្របជំនាញតិចជាង៥០% នៃកម្មវិធីសិក្សាដែលបានរៀនចប់ពីសាកលវិទ្យាល័យ។

**ក្រាភិក 10. ភាគរយធ្វើការស្របជំនាញច្រើនជាង ៥០% និងតិចជាង៥០%**




តាមក្រាភិកខាងលើបានបង្ហាញថា ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងធុរកិច្ចមាននិស្សិតជាង៦៤% មានការងារធ្វើស្របជំនាញច្រើនជាង៥០%។ ដោយឡែកចំពោះជំនាញគ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច មាននិស្សិតជា៧៨% មានការងារធ្វើស្របជំនាញតិចជាង៥០%។

### ៣.៤.៨.២. ភាពមានការងារធ្វើមិនស្របជំនាញ

ជាធម្មតានិស្សិតបានរៀនចប់លើជំនាញអ្វីតែងតែស្វែងរកការងារធ្វើលើជំនាញនោះ។ ប៉ុន្តែភាពមានការងារធ្វើវាក៏អាចអាស្រ័យលើចំណង់ចំណូលចិត្តរបស់និស្សិតបញ្ចប់ការសិក្សាផងដែរ ឬអាចនឹងមាននិស្សិតមួយចំនួនបានសម្រេចចិត្តរកការងារធ្វើអាស្រ័យតាមកត្តាផ្សេងៗ ដែលទាក់ទងទៅនឹងស្ថានភាពជីវភាពរស់នៅទៅតាមកាលៈទេសៈដែលតម្រូវឲ្យ។ ជាបន្តយើងនឹងពិនិត្យមើលលទ្ធផលនៃការទទួលបានការងារករណីមិនស្របជំនាញ។

**ក្រាភិក 11. ភាពមានការងារធ្វើមិនស្របតាមជំនាញ**




ក្រាភិកខាងលើបានបង្ហាញថា ការប្រែប្រួលភាពមានការងារធ្វើមិនស្របជំនាញអាស្រ័យទៅតាមកត្តាផ្សេងៗ មានដូចជា ទី១. ទទួលបានប្រាក់ឈ្នួលច្រើន ៧,០% ទី២. មានទីផ្សារចង្អៀត ១០,៣% ទី៣. មានអាជីវកម្មផ្ទាល់ខ្លួន ៦,៦% ទី៤. តាមតម្រូវការទីផ្សារ ១៨,៥% ទី៥. តាមចំណង់ចំណូលចិត្ត ២៣,៣% និងទី៦. ការងារផ្សេងៗមាន ៣៤,២%។

### ៣.៤.៩. ការទទួលបានប្រាក់ចំណូលប្រចាំខែ

ប្រាក់ចំណូលប្រចាំខែមានការប្រែប្រួលខ្លាំង និងផ្តុំនៅចន្លោះ ២០០$-៤០០$ និង ៤០១$-៦០០$។ ប្រាក់ឈ្នួលលើសពី ៦០០$ គឺមានកម្រិតភាគរយតិចតួចគួរឲ្យកត់សម្គាល់។

**តារាង 18. ប្រាក់ចំណូលប្រចាំខែ**




ប្រាក់ចំណូលប្រចាំខែរបស់និស្សិតដែលបានបញ្ចប់ការសិក្សាកាលពីឆ្នាំសិក្សា ២០២០-២០២១ ហើយបានផ្តល់ព័ត៌មានស្តីពីប្រាក់ឈ្នួលតាមរយៈកម្រងសំណួរនៅចន្លោះថ្ងៃទី២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ បានឲ្យដឹងថានិស្សិតទទួលបានប្រាក់ចំណូលប្រចាំខែច្រើនជាងគេគឺចន្លោះ ២០១$-៤០០$ មានចំនួន ៦៨,១%។

ករណីបើប្រៀបធៀបជាមួយអ្នកគ្មានជំនាញដែលទទួលបានប្រាក់ឈ្នួលជាមធ្យមប្រចាំខែ ២០០$ គឺមាន

ពីរករណីដែលគួរចាប់អារម្មណ៍ទី១. ប្រាក់ចំណូលប្រចាំខែនៅចន្លោះ ៨០១$-១០០០$ ស្មើនឹង ១,៩% ដែលអាចទទួលបានប្រាក់ចំណូលយ៉ាងតិច៤ដង បើធៀបនឹងកម្មករគ្មានជំនាញ និងទី២. ប្រាក់ចំណូលប្រចាំខែច្រើនជាង ១០០០$ ស្មើនឹង ២,៣% ដែលអាចទទួលបានប្រាក់ចំណូលយ៉ាងតិច៥ដង បើធៀបនឹងកម្មករគ្មានជំនាញ។

**តារាង 19. តេស្តលទ្ធផលទាក់ទងការផ្តល់ប្រាក់ឈ្នួលតាមភេទ និងធ្វើការត្រូវតាមជំនាញ**

| Variable | Label | Mean | SD | t | Sig. |
|---|---|---|---|---|---|
| Salary ($) | Male | 2.56 | 1.115 | 4.353 | 0.000 |
| | Female | 2.24 | 0.776 | | |
| High INC | Job match more than 50% | 0.055 | 0.228 | 2.032 | 0.000 |
| | Job match less than 50% | 0.024 | 0.153 | | |

***: significant risk at 1%, **: significant risk at 5%, *: significant risk at 10%

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធី Independent sample t-test ប្រៀបធៀបគម្លាតប្រាក់ខែមធ្យម បង្ហាញថា៖

- *ប្រាក់ខែមធ្យមរបស់បុរស* ទំនងមានភាពខុសគ្នា *ច្រើន* រវាងនារីក្នុងកម្រិតនៃភាពជឿជាក់ ៩៥%
- *អ្នកធ្វើការត្រូវជំនាញច្រើនជាង៥០%* ទំនងមានភាពខុសគ្នាច្រើន *ក្នុងការទទួលបានប្រាក់ចំណូលច្រើន* រវាងអ្នកធ្វើការត្រូវជំនាញទាបជាង៥០% ក្នុងកម្រិតនៃភាពជឿជាក់ ៩៥%។

## ៣.៤.១០. ករណីនានាដែលមិនទាន់មានការងារធ្វើ

ក្រាភិក 12. ករណីនានាដែលមិនទាន់មានការងារធ្វើ




បញ្ហាគ្មានការងារធ្វើគឺជាផលវិបាកនៃកត្តាអភិវឌ្ឍសេដ្ឋកិច្ចនិងកំណើន។ ការកើនឡើងនៃចំនួនការងារថ្មីៗដែលជាផលរបស់ការវិនិយោគទាំងនៅក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស(FDI)។ នៅលើក្រាភិកបង្ហាញពីកត្តាមួយចំនួននៃភាពមិនទាន់មានការងារធ្វើ៖ ទី១. ពិបាករកការងារធ្វើមានចំនួន ១៤,៦% ទី២. ការងារខុសជំនាញមានចំនួន១៣,៧% ទី៣. កំពុងរៀនបន្តមានចំនួន ៧,៥% ទី៤. មានគ្រួសារមានចំនួន ២,៨% ទី៥. ផ្លាស់ប្តូរទីលំនៅមានចំនួន ២,៤% និងទី៦. ផ្សេងៗមានចំនួន ៥៨,៩%។

### ៣.៤.១១. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា

និស្សិតក្រោយពីបញ្ចប់ការសិក្សាភ្លាមពួកគេបានស្វះស្វែងរកការងារធ្វើភ្លាមដែរ។ ប៉ុន្តែក៏មាននិស្សិតមួយចំនួនមានការងារធ្វើតាំងតែពីពេលកំពុងរៀននៅឡើយ។ តទៅនេះយើងនឹងបានឃើញពីស្ថានភាពពេលវេលាដែលនិស្សិតស្វែងរកការងារធ្វើ។

ក្រាភិក 13. រយៈពេលនៃការស្វែងរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា




ក្រាភិកខាងលើបានបង្ហាញឲ្យឃើញថា និស្សិតភាគច្រើនមានការងារធ្វើតាំងពីកំពុងនៅរៀន ឬមានន័យថាមានការងារធ្វើមុនពេលបញ្ចប់ការសិក្សា ដែលមានរហូតដល់ ៤១,០%។ ដោយឡែកនិស្សិតមាន១៨,៨% ចំណាយពេលរកការងារធ្វើតិចជាង១ខែ និងនិស្សិតមាន ១៩,២% ចំណាយពេលរកការងារធ្វើនៅចន្លោះពី ១ខែ ទៅ ៣ខែ បន្ទាប់ពីបញ្ចប់ការសិក្សា។

**តារាង 20. តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| Duration of the Job | 741 | 2.52 | 1.800 | 38.046 | 0.000 | 2.39 | 2.65 |

***: Significant risk at 1%, **: Significant risk at 5%, *: Significant risk at 10%

រយៈពេលនៃការរកការងារធ្វើ និស្សិតប្រមាណជិត ៨០,០% អាចនឹងទទួលបានការងារធ្វើដោយចំណាយពេលតិចជាង៣ខែ នេះបើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥%។

### ៣.៤.១២. ការចំណាយពេលដើម្បីទទួលបានការងារស្របជំនាញ

ការងារស្របជំនាញគឺជាការងារដែលត្រូវធ្វើតាមចំណេះ ជំនាញក្នុងកិច្ចការជាក់ស្តែងស្របតាមទ្រឹស្តីដែលបានសិក្សានៅតាមគ្រឹះស្ថានសិក្សា។ និស្សិតបញ្ចប់ការសិក្សាបានយកទ្រឹស្តីដែលបានសិក្សាពីសាលាទៅប្រើប្រាស់ និងអនុវត្តបានយ៉ាងប៉ិនប្រសប់នៅតាមបណ្តាអង្គភាពរដ្ឋ ឬសហគ្រាសអាជីវកម្មនានាក្នុងវិស័យឯកជន។

**ក្រាភិក 14. រយៈពេលទទួលបានការងារធ្វើស្របជំនាញ**




តាមក្រាភិកបានបង្ហាញថា មុនពេលបញ្ចប់ការសិក្សានិស្សិតទទួលបានការងារធ្វើស្របជំនាញច្រើនជាង ៥០% មានចំនួនច្រើនជាងគេគឺ៦៣,៥%។ គួរកត់សម្គាល់ ការចំណាយពេលចន្លោះ១ខែ ទៅ ៣ខែ និងការចំណាយពេលចន្លោះ៣ខែ ទៅ ៦ខែ ដើម្បីទទួលបានការងារធ្វើស្របជំនាញច្រើនជាង៥០% មានជាង៦០%។ ដោយឡែកការចំណាយពេលច្រើនជាង១២ខែ ដើម្បីទទួលបានការងារធ្វើស្របជំនាញច្រើនជាង៥០% មានតែ ៤៩,១% ប៉ុណ្ណោះ។

### ៣.៤.១៣. ការបង្កើតសហគ្រាសផ្ទាល់ខ្លួន

#### ៣.៤.១៣.១. ការចំណាយពេលដើម្បីបង្កើតសហគ្រាសផ្ទាល់ខ្លួន

ការបង្កើតសហគ្រាមួយទាមទារនូវការគិតពិចារណាបានល្អិតល្អន់មានដូចជា យុទ្ធសាស្ត្រអាជីវកម្ម ការគ្រប់គ្រងសហគ្រាស ការគ្រប់គ្រងហិរញ្ញវត្ថុ និងសកម្មភាពអាជីវកម្មផ្សេងទៀតដែលមានជាប់ពាក់ព័ន្ធគ្នា។ បន្ថែមលើនេះយើងនឹងពិនិត្យលើរយៈពេលសម្រាប់បង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនរបស់និស្សិតបញ្ចប់ការសិក្សា។

ការរៀបចំផែនការអាជីវកម្ម ការខិតខំខ្លាំងក្លា និងការចំណាយពេលធ្វើយ៉ាងណាដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួនទោះបីក្នុងទំហំជាអាជីវកម្មខ្នាតតូច ឬអាជីវកម្មខ្នាតមធ្យម ឬអាជីវកម្មខ្នាតធំក្តី។

**តារាង 21. ការចំណាយពេលវេលាដើម្បីបង្កើតអាជីវកម្ម**

| ទំហំនៃអាជីវកម្ម និងការចំណាយពេលវេលាដើម្បីបង្កើតអាជីវកម្ម | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចន្លោះពេលចំណាយពេលវេលាបង្កើតអាជីវកម្ម | | | | | | | |
| | | មុនពេលបញ្ចប់ការសិក្សា | ក្រោយពេលបញ្ចប់ការសិក្សា | | | | | | សរុប |
| | | | តិចជាង ១ខែ | ចន្លោះពី១ ទៅ៣ខែ | ចន្លោះពី ៣ទៅ៦ខែ | ចន្លោះពី ៦ទៅ៩ខែ | ចន្លោះពី៩ ទៅ១២ខែ | ច្រើនជាង ១២ខែ | |
| អាជីវកម្មខ្នាតតូច | ចំនួន | 17 | 1 | 4 | 4 | 3 | 3 | 4 | 36 |
| | % | 47.2% | 2.8% | 11.1% | 11.1% | 8.3% | 8.3% | 11.1% | 100% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អាជីវកម្មខ្នាតមធ្យម | ចំនួន | 2 | 1 | 2 | 1 | 0 | 0 | 1 | 7 |
| | % | 28.6% | 14.3% | 28.6% | 14.3% | 0.0% | 0.0% | 14.3% | 100% |
| អាជីវកម្មខ្នាតធំ | ចំនួន | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 |
| | % | 100.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 100% |
| អាជីវកម្មផ្សេងទៀត | ចំនួន | 8 | 1 | 1 | 0 | 1 | 3 | 3 | 17 |
| | % | 47.1% | 5.9% | 5.9% | 0.0% | 5.9% | 17.6% | 17.6% | 100% |
| **សរុប** | **ចំនួន** | **28** | **3** | **7** | **5** | **4** | **6** | **8** | **61** |
| | **%** | **45.9%** | **4.9%** | **11.5%** | **8.2%** | **6.6%** | **9.8%** | **13.1%** | **100%** |

នៅលើតារាងបង្ហាញពីការចំណាយពេលវេលាផ្សេងៗគ្នាសម្រាប់បង្កើតអាជីវកម្មផ្ទាល់ខ្លួន និងប្រែប្រួលទៅតាមទំហំនៃអាជីវកម្ម។ ចំពោះអាជីវកម្មខ្នាតតូចចំនួន ៣៦ករណី មានចំនួន ១៧ករណី ស្មើនឹង ៤៧,២% បានបង្កើតតាំងពីមុនបញ្ចប់ការសិក្សា និងមានការប្រែប្រួលទៅតាមករណីបន្តបន្ទាប់ទៀត។ អាជីវកម្មខ្នាតមធ្យមចំនួន៧ករណី មានចំនួន ២ករណី ស្មើនឹង ២៨,៦% បានបង្កើតតាំងពីមុនបញ្ចប់ការសិក្សា និងមានការប្រែប្រួលទៅតាមករណីបន្តបន្ទាប់ទៀត។ អាជីវកម្មខ្នាតធំមានចំនួនតែ ១ករណីគត់ ស្មើនឹង ១០០% បានបង្កើតតាំងពីមុនបញ្ចប់ការសិក្សា។ អាជីវកម្មផ្សេងទៀតចំនួន ១៧ករណី មានចំនួន ៨ករណី ស្មើនឹង ៤៧,១% បានបង្កើតតាំងពីមុនបញ្ចប់ការសិក្សា និងមានការប្រែប្រួលទៅតាមករណីបន្តបន្ទាប់ទៀត។

### ៣.៤.១៣.២. ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញ

ការបង្កើតសហគ្រាសអាជីវកម្មខ្លះមិនទាមទារ ឬតម្រូវការជំនាញជាក់លាក់ទេ គឺធ្វើយ៉ាងណាឲ្យអាជីវកម្មនោះមានដំណើរការបានល្អប្រសើរគឺគេអាចចាត់ទុកថាជាអាជីវកម្មមួយទទួលបានជោគជ័យ។ ប៉ុន្តែបើទោះបីជាមានករណីបែបនេះក្តី ក៏នៅមានករណីពិសេសជាច្រើនទៀតដែលបានកំណត់ពីការរៀបចំបើកដំណើរការអាជីវកម្មមួយឲ្យស្របតាមជំនាញដែលបានសិក្សាពីសាកលវិទ្យាល័យក្នុងគោលបំណងធានាភាពរឹងមាំ និងស្ថេរភាពនៃអាជីវកម្មយូរអង្វែង។ តទៅនេះយើងនឹងសិក្សារយៈពេលករណីនៃការបង្កើតអាជីវកម្មស្របជំនាញ។

**តារាង 22. ការបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញ**

| **ការបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញ** | | | |
|---|---|---|---|
| | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
| សហគ្រាសខ្នាតតូចស្របជំនាញ | 26 | 61.9% | 61.9% |
| សហគ្រាសខ្នាតមធ្យមស្របជំនាញ | 6 | 14.3% | 76.2% |
| សហគ្រាសខ្នាតធំស្របជំនាញ | 1 | 2.4% | 78.6% |
| សហគ្រាសផ្សេងស្របជំនាញ | 9 | 21.4% | 100% |
| **សរុប** | 42 | 100% | |

នៅលើតារាងខាងលើបានបង្ហាញថា ការបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនស្របជំនាញមានចំនួនច្រើនជាងគេ គឺការបង្កើតសហគ្រាសខ្នាតតូចស្មើនឹង ៦១,៩% ។ ការចំណាយពេលដើម្បីបង្កើតសហគ្រាសផ្ទាល់ខ្លួនស្របជំនាញមានការប្រប្រួលពេលវេលាអាស្រ័យតាមទំហំសហគ្រាសដែរ។

តារាង 23. ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មស្របជំនាញផ្ទាល់ខ្លួន

| ការចំណាយពេលបង្កើតសហគ្រាសអាជីវកម្មស្របជំនាញផ្ទាល់ខ្លួន | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចន្លោះពេលចំណាយពេលវេលាបង្កើតអាជីវកម្ម | | | | | | | |
| | | មុនពេលបញ្ចប់ការសិក្សា | ក្រោយពេលបញ្ចប់ការសិក្សា | | | | | | សរុប |
| | | | តិចជាង ១ខែ | ចន្លោះពី១ ទៅ៣ខែ | ចន្លោះពី ៣ទៅ៦ខែ | ចន្លោះពី ៦ទៅ៩ខែ | ចន្លោះពី៩ ទៅ១២ខែ | ច្រើនជាង ១២ខែ | |
| អាជីវកម្មខ្នាតតូច | ចំនួន | 11 | 1 | 2 | 2 | 3 | 3 | 2 | 24 |
| | % | 45.8% | 4.2% | 8.3% | 8.3% | 12.5% | 12.5% | 8.3% | 100% |
| អាជីវកម្មខ្នាតមធ្យម | ចំនួន | 2 | 1 | 2 | 1 | 0 | 0 | 0 | 6 |
| | % | 33.3% | 16.7% | 33.3% | 16.7% | 0.0% | 0.0% | 0.0% | 100% |
| អាជីវកម្មខ្នាតធំ | ចំនួន | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 |
| | % | 100.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 100% |
| អាជីវកម្មផ្សេងទៀត | ចំនួន | 5 | 1 | 0 | 0 | 0 | 1 | 0 | 7 |
| | % | 71.4% | 14.3% | 0.0% | 0.0% | 0.0% | 14.3% | 0.0% | 100% |
| **សរុប** | **ចំនួន** | **19** | **3** | **4** | **3** | **3** | **4** | **2** | **38** |
| | **%** | **50.0%** | **7.9%** | **10.5%** | **7.9%** | **7.9%** | **10.5%** | **5.3%** | **100%** |

លើតារាងខាងលើបានបង្ហាញថា ការបង្កើតសហគ្រាសអាជីវកម្មស្របជំនាញ ភាគច្រើនគឺមុខពេលបញ្ចប់ការសិក្សាមានរហូតដល់៥០%។ ក្នុងនោះ ការបង្កើតសហគ្រាសអាជីវកម្មស្របជំនាញ ខ្នាតតូចមានចំនួន៤៥%។ ដោយឡែកក្រោយបញ្ចប់ការសិក្សា ការបង្កើតសហគ្រាសអាជីវកម្មស្របជំនាញ នៅចន្លោះពេលពី១ខែទៅ៣ខែ និងចន្លោះពី៩ខែទៅ១២ខែ មានចំនួន១០.៥%។

## ៣.៥. ព័ត៌មានពីតម្រូវការមុខជំនាញ

ប្រសិទ្ធភាពការងារគឺជាការបំពេញការងារបានតាមផែនការកំណត់ទាំងបរិមាណ និងគុណភាព។ សមិទ្ធិផលទាំងនោះកើតចេញពីការងារស្របជំនាញដែលទទួលបានចំណេះ ជំនាញពីការបណ្តុះបណ្តាលនៅគ្រឹះស្ថានអប់រំ។ ផលិតភាពនៃការងារស្របជំនាញតែងតែមានគុណតម្លៃខ្ពស់ទាំងតម្លៃ បរិមាណ និងគុណភាព។ ជាបន្តយើងនឹងសិក្សាពិនិត្យមើលការវាយតម្លៃការងារតាមរយៈជំនាញដែលបានសិក្សាកន្លងមក។

តារាងផ្តល់សារៈសំខាន់ចំពោះតម្រូវការបំណិនជំនាញសម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន

### ៣.៥.១. តម្រូវការបំណិនជំនាញសម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន

តារាង 24. តម្រូវការបំណិនជំនាញសម្រាប់ការងារ

| លរ | បំណិនជំនាញមានសារៈសំខាន់ | ចាំបាច់តិចតួច | ចាំបាច់មធ្យម | ចាំបាច់បង្គួរ | ចាំបាច់ខ្លាំង | ចាំបាច់ខ្លាំងណាស់ |
|---|---|---|---|---|---|---|
| ១ | សមត្ថភាពបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ | 1.4% | 4.5% | 24.4% | 29.5% | 40.2% |
| ២ | សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរ | 0.9% | 4.9% | 31.0% | 29.1% | 34.1% |
| ៣ | ការគិតត្រិះរិះពិចារណា | N/A | 2.5% | 20.5% | 28.0% | 49.0% |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ | 0.3% | 1.4% | 14.7% | 23.1% | 60.5% |
| ៥ | សមត្ថភាពធ្វើការងារជាក្រុម | 0.5% | 4.3% | 20.8% | 30.6% | 43.8% |
| ៦ | សមត្ថភាពបង្កើតទំនាក់ទំនងអន្តរបុគ្គល | N/A | 1.6% | 13.4% | 24.8% | 60.2% |
| ៧ | ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន | 0.3% | 3.6% | 22.4% | 30.6% | 43.2% |
| ៨ | ភាពជាអ្នកដឹកនាំ | 0.3% | 2.6% | 18.1% | 27.4% | 51.7% |

តារាងខាងលើបានបង្ហាញថា តម្រូវការបំណិនជំនាញដែលមានសារៈសំខាន់សម្រាប់ការងារដែលកំពុងធ្វើបច្ចុប្បន្ន ទី១.សមត្ថភាពបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ កម្រិតចាំបាច់ខ្លាំងណាស់មាន ៥០,២% ទី២. សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរ កម្រិតចាំបាច់ខ្លាំងណាស់មាន ៣៤,១% ទី៣. ការគិតត្រិះរិះពិចារណា កម្រិតចាំបាច់ខ្លាំងណាស់មាន ៤៩,០% ទី៤. សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ កម្រិតចាំបាច់ខ្លាំងណាស់មាន ៦០,៥% ទី៥. សមត្ថភាពធ្វើការងារជាក្រុម កម្រិតចាំបាច់ខ្លាំងណាស់មាន ៤៣,៨% ទី៦. សមត្ថភាពបង្កើតទំនាក់ទំនងអន្តរបុគ្គល កម្រិតចាំបាច់ខ្លាំងណាស់មាន ៦០,២% ទី៧. ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន កម្រិតចាំបាច់ខ្លាំងណាស់មាន ៤៣,២% និងទី៨. ភាពជាអ្នកដឹកនាំ កម្រិតចាំបាច់ខ្លាំងណាស់មាន ៥១,៧%។

**តារាង 25. តេស្តលទ្ធផលទាក់ទងជាមួយបំណិតលើជំនាញនីមួយៗ**

| Variable / Management | Major | High Income p-value | Entrepreneurship p-value | Leadership p-value | decision making p-value | Goal of working p-value |
|---|---|---|---|---|---|---|
| | Development | **0.010*** | 0.282 | 0.306 | 0.915 | 0.262 |
| | Accounting | **0.001***** | 0.109 | **0.008***** | 0.188 | **0.002***** |
| | Banking and Finance | **0.000***** | **0.019**** | **0.042**** | 0.701 | **0.000***** |
| | Tourism and Hospitality | **0.038*** | 0.381 | 0.417 | 0.284 | 0.478 |
| | F | 4.234 | 1.450 | 1.970 | 0.715 | 4.159 |
| | Sig. | 0.002*** | 0.216 | 0.097* | 0.582 | 0.002*** |
| | N | 746 | 773 | 773 | 773 | 740 |

***: significant risk at 1%, **: significant risk at 5%, *: significant risk at 10%

តារាងខាងលើបានបង្ហាញថា ៖

លទ្ធផលតេស្ត ANOVA តាមវិធីប្រៀបធៀបភាពខុសយ៉ាងសំខាន់(LSD)ត្រង់កម្រិតជឿជាក់៩៥% ÷

- ជំនាញគ្រប់គ្រងធុរកិច្ចមាន «***ប្រាក់ចំណូលខ្ពស់***»ប្រសើរជាងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញ*ទេសចរណ៍និងបដិសណ្ឋារកិច្ច*។
- ជំនាញគ្រប់គ្រងធុរកិច្ចមាន «***ភាពជាសហគ្រិន***»ប្រសើរជាងជំនាញ*ធនាគារនិងហិរញ្ញវត្ថុ* លើកលែងជំនាញ *សេដ្ឋកិច្ចអភិវឌ្ឍន៍* ជំនាញ*គណនេយ្យ* និងជំនាញ*ទេសចរណ៍និងបដិសណ្ឋារកិច្ច* ដែលមានលក្ខណៈមិនខុសគ្នាលើបំណិន***ភាពជាសហគ្រិន***។
- ជំនាញគ្រប់គ្រងធុរកិច្ចមាន «***ភាពជាអ្នកដឹកនាំ***»ប្រសើរជាងជំនាញ*គណនេយ្យ* និងជំនាញ*ធនាគារនិងហិរញ្ញវត្ថុ* លើកលែងជំនាញ*សេដ្ឋកិច្ចអភិវឌ្ឍន៍* និងជំនាញ*ទេសចរណ៍និងបដិសណ្ឋារកិច្ច* ដែលមានលក្ខណៈមិនខុសគ្នាលើបំណិន***ភាពជាអ្នកដឹកនាំ***។
- ជំនាញគ្រប់គ្រងធុរកិច្ចគ្មានភាពខុសគ្នាក្នុងបំណិន «***ការសម្រេចចិត្ត***»ជាមួយជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញ*ទេសចរណ៍និងបដិសណ្ឋារកិច្ច* នោះទេ។
- ជំនាញគ្រប់គ្រងធុរកិច្ចមានតម្រូវការ«***សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ***» ច្រើនជាងជំនាញគណនេយ្យ

និងជំនាញធនាគារនិងហិរញ្ញវត្ថុ លើកលែងជំនាញ*សេដ្ឋកិច្ចអភិវឌ្ឍន៍* និង*ទេសចរណ៍និងបដិសណ្ឋារកិច្ច* ដែលមានលក្ខណៈមិនខុសគ្នាលើបំណិននៃ***សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ***។

### ៣.៥.២. ការប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារប្រចាំថ្ងៃ

ការដំណើរការអាជីវកម្មនៅក្នុងអង្គភាពអាជីវកម្ម ឬស្ថាប័នរដ្ឋក្តី ការងារនីមួយៗគឺតម្រូវឲ្យបុគ្គលិកមានការទទួលខុសត្រូវខ្ពស់ទៅលើសកម្មភាពការងារនិងលទ្ធផលការងារដែលទទួលបាន។ ចំណុចទាំងអស់នេះទាមទារឲ្យបុគ្គលិកក៏ដូចជាអ្នកទទួលខុសត្រូវនៅតាមលំដាប់ថ្នាក់ធ្វើការឲ្យអស់ពីសមត្ថភាព ទៅតាមកម្រិតចំណេះដឹងដែលទទួលបានពីការសិក្សារបស់ខ្លួនដែលរៀនកន្លងមក។ តទៅនេះយើងនឹងសិក្សាលើការប្រើប្រាស់សមត្ថភាព ចំណេះដឹងរបស់និស្សិតបញ្ចប់ការសិក្សានៅតាមជំនាញនីមួយៗ។

**តារាង 26. កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ**

| កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ | | | |
|---|---|---|---|
| | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
| ប្រើចំណេះដឹងទាបជាងកម្រិតសញ្ញាបត្រ | 92 | 11.9% | 11.9% |
| ប្រើចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រ | 549 | 71.3% | 83.2% |
| ប្រើចំណេះដឹងខ្ពស់ជាងកម្រិតសញ្ញាបត្រ | 129 | 16.8% | 100% |
| **សរុប** | **770** | **100%** | |

តារាងខាងលើបានបង្ហាញថា និស្សិតបានប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារត្រូវនឹងសញ្ញាបត្ររបស់ខ្លួនមានរហូតដល់ ៧១,៣% នៃនិស្សិតសរុបចំនួន៧៧០នាក់។ ចំណែកនិស្សិតបានប្រើប្រាស់ចំណេះដឹងក្នុងការបំពេញការងារទាបជាងសញ្ញាបត្ររបស់ខ្លួនមានតែ ១១,៩% ប៉ុណ្ណោះ។ បន្ថែមលើនេះ យើងនឹងពិនិត្យលើជំនាញនីមួយៗស្តីពីការប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រដើម្បីបំពេញការងារ។

**ក្រាភិក 15. កម្រិតប្រែប្រួលនៃការប្រើប្រាស់ចំណេះដឹងក្នុងការងារធៀបនឹងសញ្ញាបត្រជំនាញ**




ក្រាភិកបានបង្ហាញថា គ្រប់ជំនាញទាំងអស់សុទ្ធតែបានប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្ររបស់ខ្លួន ជាពិសេសជំនាញគ្រប់គ្រងធុរកិច្ច និងជំនាញគណនេយ្យបានប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្ររបស់ខ្លួន មានរហូតដល់ជាង៧០%។

## ៣.៦. ព័ត៌មានពីមតិយោបល់របស់អ្នកចូលរួម

នៅតាមសាកលវិទ្យាល័យមានការិយាល័យសេវានិស្សិត ដែលមានភារកិច្ចជួយដោះស្រាយដល់តម្រូវការផ្សេងៗដែលនិស្សិតអាចទទួលបានពីសាកលវិទ្យាល័យជាពិសេសព័ត៌មានការស្វែងរកការងារធ្វើទៅកាន់និស្សិត។ តទៅនេះយើងពិនិត្យលទ្ធភាពខ្លះៗដែលនិស្សិតបានទទួលសេវានានាពីសាកលវិទ្យាល័យ និងស្តាប់ព័ត៌មាន ឬសំណូមពរត្រឡប់ពីនិស្សិតវិញ។

### ៣.៦.១. ការជួយនិស្សិតដើម្បីទទួលបានការងារ

ជារៀងរាល់ឆ្នាំ សាកលវិទ្យាល័យបានផ្តល់ព័ត៌មានទៅកាន់និស្សិតតាមរយៈការផ្សព្វផ្សាយមានដូចជា ខិត្តប័ណ្ណ ធ្វើសិក្ខាសាលាផ្សព្វផ្សាយ ឬបង្ហាញការស្វែងរកការងាររយៈ website ជាដើម ក្នុងគោលបំណងឲ្យនិស្សិតបានដឹងព័ត៌មាននៃតម្រូវការការងារ។

**តារាង 27. ការជួយនិស្សិតដើម្បីទទួលបានការងារ**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| មិនបានជួយ | 28 | 3.6% | 3.6% |
| បានជួយតិចតួច | 69 | 8.9% | 12.5% |
| បានជួយមធ្យម | 206 | 26.6% | 39.1% |
| បានជួយបង្គួរ | 236 | 30.5% | 69.6% |
| បានជួយច្រើន | 235 | 30.4% | 100% |
| **សរុប** | **774** | **100%** | |

តាមលទ្ធផលបង្ហាញថាក្នុងការទទួលបានការងារ មាន ៣០,៤% ថាបានជួយច្រើន ៣០,៥% ថាបានជួយបង្គួរ និង២៦,៦% ថាបានជួយមធ្យម ខណៈមាន ៨,៩% ថាបានជួយតិចតួចនិង ៣,៦% ថាមិនបានជួយ។

**តារាង 28. តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| RULE supporting to get the Job | 774 | **3.75** | 1.091 | 95.602 | 0.000 | 3.67 | 3.83 |

***: Significant risk at 1%, **: Significant risk at 5%, *: Significant risk at 10%

បើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥%នេះ លទ្ធផលបង្ហាញថានិស្សិតប្រមាណ ៧០,០% បានវាយតម្លៃថាបានជួយនិស្សិតដល់ ***កម្រិតច្រើនបង្គួរ*** ក្នុងការទទួលបានការងារធ្វើ។

### ៣.៦.២. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ

នៅក្នុងស្ថាប័នរដ្ឋ ឬនៅតាមបណ្តាអង្គភាពអាជីវកម្មនានានៅពេលដែលមានការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មី ឬបំពាក់បច្ចេកទេសថ្មីតែងតែរៀបចំធ្វើការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួនទៅតាមពេលវេលាត្រឹមត្រូវ ដល់មនុស្សត្រឹមត្រូវ និងសមត្ថភាពត្រឹមត្រូវ។ តទៅនេះយើងនឹងបានដឹងព័ត៌មានត្រឡប់។

**តារាង 29. ការបណ្តុះបណ្តាលបន្ថែមនៅកន្លែងការងារ**

| | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
|---|---|---|---|
| បានទទួលការបណ្តុះបណ្តាល | 678 | 87.6% | 87.6% |
| មិនបានទទួលការបណ្តុះបណ្តាល | 96 | 12.4% | 100% |
| **សរុប** | **774** | **100%** | |

ជាលទ្ធផលបង្ហាញថា ៨៧,៦% ទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែមនៅកន្លែងការងារ ខណៈដែលមាន ១២,៤% ផ្សេងទៀតមិនទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែម។

### ៣.៦.៣. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត

នៅពេលទទួលបានការងារធ្វើរួចហើយ វាអាចមាននិស្សិតមួយចំនួនសម្រេចចិត្តបន្តការសិក្សាលើបរិញ្ញាបត្រជំនាញផ្សេងបន្ថែម ឬបន្តទៅសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ទៀតដើម្បីបំពេញចន្លោះតម្រូវការទីផ្សារការងារដែលមានការប្រែប្រួលថ្មីៗ។ តទៅនេះយើងនឹងបានដឹងព័ត៌មានត្រឡប់ដែលមានសារៈសំខាន់។

**តារាង 30. ការសិក្សាបន្តទៅកម្រិតសញ្ញាបត្រផ្សេងទៀត**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| បានសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត | 70 | 9.3% | 9.3% |
| បានសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | 33 | 4.4% | 13.6% |
| បានសិក្សាកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ | 9 | 1.2% | 14.8% |
| មិនបានបន្តការសិក្សា | 643 | 85.2% | 100% |
| **សរុប** | **755** | **100%** | |

ជាលទ្ធផលមាននិស្សិតបានសិក្សាបន្ថែមនូវកម្រិតបរិញ្ញាបត្រផ្សេងទៀតមានចំនួន ៩,៣% បានសិក្សាបន្តទៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤,៤% បានសិក្សាបន្ថែមទាំងកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១,២% ខណៈមាននិស្សិតមិនបានបន្តការសិក្សាមានចំនួន ៨៥,២%។

### ៣.៦.៤. ការសិក្សាជំនាញខ្លីៗ

ការបំពេញការងារប្រចាំថ្ងៃតែងជួបនូវការខ្វះចន្លោះបច្ចេកទេសសម្រាប់ដោះស្រាយការងារចៀសពុំរួច។ ដើម្បីដោះស្រាយបញ្ហាទាំងនោះ ការឆ្លៀតពេលទៅរៀនវគ្គសិក្សាជំនាញខ្លីៗគឺមានសារៈសំខាន់សម្រាប់មនុស្សដែលមានភាពឧស្សាហ៍ព្យាយាម។ យើងនឹងពិនិត្យភាពជាក់ស្តែងនៃការសិក្សាជំនាញខ្លីៗ។

**តារាង 31. ការសិក្សាជំនាញខ្លីៗ**

| | **ចំនួន** | **ភាគរយ** | **ភាគរយបូកបង្គរ** |
|---|---|---|---|
| បានសិក្សានិងបញ្ចប់ដោយជោគជ័យ | 69 | 9.2% | 9.2% |
| កំពុងសិក្សាជំនាញខ្លីៗ | 141 | 18.8% | 28.0% |
| មិនបានសិក្សា | 541 | 72.0% | 100% |
| **សរុប** | **751** | **100%** | |

ជាលទ្ធផលនិស្សិតបានសិក្សាជំនាញខ្លីៗនិងបានបញ្ចប់ដោយជោគជ័យមានចំនួន ៩,២% និស្សិតកំពុងសិក្សាជំនាញខ្លីៗមានចំនួន ១៨,៨% ខណៈមាននិស្សិត ៧២,០% មិនបានសិក្សាជំនាញខ្លីអ្វីទេ។

### ៣.៦.៥. ការចូលរួមសកម្មភាពសង្គម

ការងារសង្គមជាសកម្មភាពសប្បុរសធម៌មួយបែបដែលត្រូវបានគេនិយមប្រើប្រាស់សង្គម ឬប្រទេសសម័យទំនើប ឬអាចនិយាយម្យ៉ាងទៀតថាប្រទេសរីកចំរើនគឺសំដៅដល់អ្នកមានសមត្ថភាព មានបទពិសោធន៍ ឬមានធនធាន ដើម្បីចែករំលែកអ្វីទាំងអស់នោះទៅកាន់អ្នករស់នៅក្នុងតំបន់កំពុងអភិវឌ្ឍន៍ជាអាទិភាព។

**តារាង 32. ការចូលរួមសកម្មភាពសង្គម**

| | ចំនួន | ភាគរយ | ភាគរយបូកបង្គរ |
|---|---|---|---|
| មិនបានចូលរួម | 169 | 21.8% | 21.8% |
| បានចូលរួមតិចតួច | 243 | 31.4% | 53.2% |
| បានចូលរួមមធ្យម | 256 | 33.1% | 86.3% |
| បានចូលរួមបង្គួរ | 89 | 11.5% | 97.8% |
| បានចូលរួមច្រើន | 17 | 2.2% | 100% |
| សរុប | 774 | 100% | |

ជាលទ្ធផលយើងបានសង្កេតឃើញថា មានយ៉ាងហោចណាស់លើសពី ៥៣% និស្សិតបញ្ចប់ការសិក្សាបានចូលរួមក្នុងសកម្មភាពសង្គមចាប់ពីសកម្មភាពតិចតួចឡើងទៅដល់កម្រិតសកម្មភាពច្រើនដែលគួរឲ្យកត់សម្គាល់។

**តារាង 33. តេស្តលទ្ធផល**

| Label | N | Mean | SD | t | Sig. | Lower | Upper |
|---|---|---|---|---|---|---|---|
| Social Activity | 774 | 2.41 | 1.020 | 65.655 | 0.000 | 2.34 | 2.48 |

***: Significant risk at 1%, **: Significant risk at 5%, *: Significant risk at 10%

បើយោងតាមវិធីវាយតម្លៃ One Sample T-Test ក្នុងកម្រិតជឿជាក់ ៩៥% នេះលទ្ធផលបង្ហាញថានិស្សិតប្រមាណ ៨៦,០% បានវាយតម្លៃដល់ ***កម្រិតមធ្យម*** ក្នុងការងារសង្គមជាសកម្មភាពសប្បុរសធម៌។

### ៣.៦.៦. លទ្ធផលនៃកម្មវិធីសិក្សាបានឆ្លើយតបនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

កម្មវិធីសិក្សានៃមុខជំនាញនីមួយៗ ត្រូវបានរៀបចំឡើងដោយស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ដែលបានដែលផ្សព្វផ្សាយឲ្យប្រើដោយអនុក្រឹត្យស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា លេខ១៥៣ អនក្រ.បកចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤ ។ លទ្ធសិក្សានៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិ រួមមាន៖

ទី១. ចំណេះដឹង៖ នៅក្នុងចំណុចត្រេទី៣មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ *«ដំណោះស្រាយបញ្ហា»* សម្រាប់វាយតម្លៃសូចនាករទី១។

ទី២. ជំនាញក្នុងការគិត៖ នៅក្នុងចំណុចត្រេទី៣មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ *«ចំណេះដឹង»* សម្រាប់វាយតម្លៃសូចនាករទី២

ទី៣. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖ នៅក្នុងចំណុចត្រេទី១មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ «ភាពជាអ្នកដឹកនាំ» សម្រាប់វាយតម្លៃសូចនាករទី៣។

ទី៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖ នៅក្នុងចំណុចត្រេទី១មានពាក្យគន្លឹះសំខាន់មួយដែលអាចវាស់បានគឺ «*បច្ចេកវិទ្យាព័ត៌មាន*» សម្រាប់វាយតម្លៃសូចនាករទី៤។

ដូច្នេះ ដើម្បីដឹងថាកម្មវិធីសិក្សាទទួលបានលទ្ធផលរំពឹងទុកស្របតាមគុណវុឌ្ឍិជាតិដល់កម្រិតណា គឺការធ្វើតេស្តជាកត្តាសំខាន់។

**ប្រើវិធីវិភាគ** Binary Logistic Model ៖

នៅក្នុងអថេរ *យេនឌ័រ* ករណីភេទ បើ ប្រុស=1 និងផ្ទុយមកវិញ បើ ស្រី=0

ករណីអថេរផ្សេងទៀតដែលវាស់ជាគុណភាព (Dummy variable) នៅក្នុងគំរូវិភាគត្រូវកំណត់យកក្នុងបច្ចេកទេសតក្កវិទ្យា (1/0) សម្រាប់ការវិភាគនិងស្វែងរកលទ្ធផលដែលមាននៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ

លទ្ធផលត្រូវបានបង្ហាញក្នុងតារាងខាងក្រោមនេះ

**តារាង 34. ការវិភាគលទ្ធផលទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ**

| ល.រ | អថេរក្នុងគំរូវិភាគ | ដោះស្រាយបញ្ហា | ចំណេះដឹង | ភាពជាអ្នកដឹកនាំ | បច្ចេកវិទ្យាព័ត៌មាន |
|---|---|---|---|---|---|
| 1 | យេនឌ័រ | N/A | N/A | 0.314* | 0.442** |
| 2 | មានការងារធ្វើផងនិងអាជីវកម្មផង | N/A | N/A | -0.901** | N/A |
| 3 | ប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រ | 0.037** | N/A | N/A | N/A |
| 4 | ការងារស្របបច្ចេកទេស | N/A | N/A | -0.819** | N/A |
| 5 | ភាពជាអ្នកគ្រប់គ្រង | N/A | N/A | -0.604** | N/A |
| 6 | ការងារជាក្រុម | N/A | -1.037** | -0.731** | -0.685** |
| 7 | ភាពជាអ្នកដឹកនាំឆ្ពោះទៅរកគោលដៅ | N/A | -0.800*** | N/A | N/A |
| 8 | ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តន៍ | N/A | -0.618*** | -0.383** | -0.603*** |
| 9 | ភាពច្នៃប្រឌិត | 0.003*** | -1.428*** | -1.145*** | -0.985*** |
| 10 | ប្រាក់ចំណូលខ្ពស់ | N/A | -1.593*** | N/A | N/A |
| 11 | តម្លៃថេរ (Constant) | N/A | 4.129*** | 3.556*** | 1.528** |
| | ចំនួនអង្កេត | 715 | 715 | 715 | 715 |
| | R-square | 0.055 | 0.195 | 0.156 | 0.128 |

*:significant at risque 10%, **:significant at risque 5%, ***:significant at risque 1%, na: Not avalable.

**នៅលើតារាងវិភាគ លទ្ធផលបង្ហាញដូចតទៅ៖**

- ទី១. កម្រិតចំណេះដឹង៖ *ការដោះស្រាយបញ្ហា* មានទំនាក់ទំនងវិជ្ជមានជាមួយនឹង*ការប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រ* ក្នុងកម្រិតប្រូបាប៊ីលីតេ ០,០៥ និងអថេរ*ភាពច្នៃប្រឌិត* ក្នុងកម្រិតប្រូបាប៊ីលីតេ ០,០១

- ទី២. ជំនាញក្នុងការគិត៖ *ចំណេះដឹង* មានទំនាក់ទំនងប្រាសជាមួយនឹង*ការធ្វើការងារជាក្រុម* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ភាពជាអ្នកដឹកនាំឆ្ពោះទៅរកគោលដៅ* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១ អថេរ*ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តន៍* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១ អថេរ*ភាពច្នៃប្រឌិត* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១ និងអថេរ*ប្រាក់ចំណូលខ្ពស់* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១។
- ទី៣. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ÷ *ភាពជាអ្នកដឹកនាំ* មានទំនាក់ទំនងវិជ្ជាមានជាមួយនឹងអថេរ *យេនឌ័រ* ជាពិសេសភេទប្រុសនៅក្នុងកម្រិតភាពជាអ្នកដឹកនាំក្នុងកម្រិតប្រូបាប៊ីលីតេ 0,១0 និងមានទំនាក់ទំនងអវិជ្ជាមានជាមួយអេថរ*មានការងារធ្វើផងនិងអាជីវកម្មផង* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ការងារស្របបច្ចេកទេសឬជាអ្នកបច្ចេកទេស* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ភាពជាអ្នកគ្រប់គ្រង* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ការងារជាក្រុម* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តន៍*ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ និងអថេរ*ភាពច្នៃប្រឌិត* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១។
- ទី៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖ *បច្ចេកវិទ្យាព័ត៌មាន* មានទំនាក់ទំនងវិជ្ជាមានជាមួយនឹងអថេរ *យេនឌ័រ* ជាពិសេសភេទប្រុសនៅក្នុងកម្រិតបច្ចេកទេសព័ត៌មានវិទ្យាក្នុងអត្ថន័យកម្រិតប្រូបាប៊ីលីតេ 0,0៥ និងមានទំនាក់ទំនងអវិជ្ជមានជាមួយអថេរ*ការងារជាក្រុម* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0៥ អថេរ*ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តន៍* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១ និងអថេរ*ភាពច្នៃប្រឌិត* ក្នុងកម្រិតប្រូបាប៊ីលីតេ 0,0១។

## ចំណុចខ្លាំង និងចំណុចខ្វះខាត នៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីសិក្សាទាំង៥ជំនាញរួមមាន៖ ជំនាញគ្រប់គ្រងធុរកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាញគណនេយ្យ ជំនាញធនាគារនិងហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច បានអនុវត្តតាមការណែនាំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ចាប់តាំងពីឆ្នាំ ២00៤ និងជាពិសេសនៅចុងក្រោយនេះគឺបានដើតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាចាប់តាំងពីឆ្នាំ២0១៤ បន្ថែមពីលើអ្វីដែលសាកលវិទ្យាល័យបាននិងកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ន។ ជាលទ្ធផលបង្ហាញថា៖

### ចំណុចខ្លាំង

- អត្រានៃចំនួននិស្សិតដែលទទួលបានការងារធ្វើ បន្ទាប់ពីបញ្ចប់ការសិក្សានៅតែមានកម្រិតខ្ពស់ជុំវិញ ៩៧,0%
- និស្សិតរកការងារធ្វើបានភ្លាមៗមានអត្រាខ្ពស់ដល់៤១,0% ករណីមានអ្នករកបានការងារធ្វើក្នុងរយៈពេលក្រោម១ខែ មានជិត ១៩% ខណៈជាង ១៩%ទៀត រកបានការងារធ្វើនៅចន្លោះ ១ ទៅ ៣ខែ
- ប្រមាណ ៧0%នៃនិស្សិតបានប្រើប្រាស់ចំណេះដឹងបំពេញការងារស្របនឹងកម្រិតសញ្ញាបត្រ
- ជុំវិញ ៤៥% នៃនិស្សិតបញ្ចប់ការសិក្សាដែលមានអាជីវកម្មផ្ទាល់ខ្លួន ពួកគាត់បានចាប់ផ្តើមបង្កើតវាតាំងពីពេលកំពុងនៅសិក្សា
- កម្មវិធីសិក្សាបានឆ្លើយតបទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ៖ កម្រិតចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង។

**ចំណុចខ្វះចន្លោះ**

- ការបង្កើតអាជីវកម្មផ្ទាល់ខ្លួនមានចំនួនទាបក្រោម ៨,០%
- ការងារជាអ្នកបច្ចេកទេសនៅមានកម្រិតទាបជុំវិញ ៧,០% ខណៈអ្នកគ្រប់គ្រងកម្រិតខ្ពស់មាន ១,៥%
- ប្រាក់ឈ្នួលភាគច្រើននៅចន្លោះ ២០០$ ដល់ ៦០០$ មានដល់កម្រិត ៨៦,០% ខណៈអ្នកមានប្រាក់ឈ្នួលច្រើនជាង ១០០០$ ឬយ៉ាងតិចស្មើ៥ដងនៃកម្មករគ្មានជំនាញមានតែ ២,៣%
- ការវាស់សេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សា កម្រិតពេញចិត្តខ្លាំងមានតែជាង ៥០,០%។

# ផ្នែកទី៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សាស្តីពីស្ថានភាពមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំ២០២១នេះ ធ្វើឡើងដើម្បីស្វែងរកភាពខ្លាំង និងភាពខ្វះចន្លោះនៃកម្មវិធីសិក្សា។ បន្ទាប់ពីបានដឹងចំណុចទាំងអស់នេះហើយ សេចក្តីសន្និដ្ឋាននិងអនុសាសន៍មួយចំនួនបានបង្ហាញជាបន្តបន្ទាប់ខាងក្រោមនេះ

## ៤.១. ការសន្និដ្ឋាន

តាមលទ្ធផលដែលបានបង្ហាញខាងលើបញ្ជាក់ឲ្យឃើញថា កម្មវិធីបណ្តុះបណ្តាលជំនាញទាំង៥របស់មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង បានដំណើរការល្អទាំងជំនាញ ចំណេះដឹងគ្រប់គ្រាន់ដល់និស្សិតដែលអាចឲ្យពួកគេបន្ទាប់ពីបញ្ចប់ការសិក្សាទៅអាចនឹងរកការងារធ្វើបានឆាប់។ និស្សិតភាគច្រើនមានការងារធ្វើតាំងពីនៅកំពុងសិក្សា បន្ទាប់ពីនោះប្រើពេលតិចជាង១ខែ និងនៅចន្លោះពី១ខែ ទៅ ៣ខែអាចរកបានការងារធ្វើស្មើរគ្រប់គ្នា។ ភាគច្រើនមានការងារធ្វើត្រូវតាមជំនាញច្រើជាង៥០%ដែលបានសិក្សាតាមកម្មវិធីបណ្តុះបណ្តាល។ បន្ថែមពីនេះ និស្សិតមានលទ្ធភាពប្រើប្រាស់ចំណេះដឹងស្របកម្រិតសញ្ញាបត្រជិត ៧០% ក្នុងការបំពេញការងារប្រចាំថ្ងៃរបស់ពួកគេ។ ទទួលបានប្រាក់ឈ្នួលខ្ពស់យ៉ាងតិច៥ដងនៃកម្មការគ្មានជំនាញមានចំនួន ២,៣% និងមាននិស្សិតដែលមានសមត្ថភាពបង្កើតសហគ្រាសអាជីវកម្មផ្ទាល់ខ្លួនមានចំនួន ៨,៥%។ ចំណុចសំខាន់ចុងក្រោយគឺកម្មវិធីសិក្សាទាំង៥ជំនាញបានឆ្លើយតបតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិដូចបានបង្ហាញក្នុងតារាងវិភាគលេខ៣២។

## ៤.២. អានុសាសន៍

ដើម្បីឲ្យភាពខ្លាំងទាំងឡាយដែលបានលើកយកមកបង្ហាញខាងលើនេះ កាន់តែមានឧត្តមភាពបន្ថែមទៀត យើងមានចំណុចដែលគួរពិចារណាចំនួន ៣ សម្រាប់ធ្វើការពិនិត្យ និងពិចារណា៖

- គួរបង្កើនកម្រិតពេញចិត្តរបស់និស្សិតចំពោះកម្មវិធីសិក្សាឲ្យបានខ្ពស់ជាងនេះ ពីព្រោះនៅក្នុងលទ្ធផលស្រាវជ្រាវបានរកឃើញសេចក្តីពេញចិត្តចំពោះកម្មវិធីសិក្សាមានតែជាង ៥០,០%
- គួរពិនិត្យមើលឡើងវិញប្លង់មេរៀនលម្អិតតាមជំនាញនីមួយៗ ដើម្បីបំពេញកម្មវិធីសិក្សាឲ្យកាន់តែប្រសើរ
- គួរពិនិត្យមើលបច្ចេកទេសបង្រៀន ជាពិសេសការបង្រៀនផ្នែកទ្រឹស្តីផ្សារភ្ជាប់ជាមួយការអនុវត្ត។

## ៤.៣. ការងារត្រូវធ្វើបន្ត និងសំណូមពរ

លទ្ធផលស្រាវជ្រាវនេះ បានឆ្លុះបញ្ចាំងពីសកម្មភាពមួយចំនួនដែលបានជួបប្រទះនៅពេលបច្ចុប្បន្ន។ ក្នុងពេលអនាគតអ្វីៗមានការប្រែប្រួលទោះក្នុងកម្រិតណាមួយ។ ដូច្នេះ ចំណុចដែលគួរធ្វើបន្ត និងជាសំណូមពរ៖

- ទំហំកម្រិតប្រាក់ឈ្នួលទូទៅនៅទាប ប្រមាណ ៨៦% នៃនិស្សិតមានសញ្ញាបត្របរិញ្ញាបត្រទទួលបានប្រាក់ឈ្នួលនៅចន្លោះ ២០០$ ទៅ ៦០០$
- សិក្សាពីការវិវត្តទីផ្សារការងារ និងការធ្វើការងារស្របជំនាញក្រោម៥០% មានចំនួនជាង ៤០% និងទទួលបានឈ្នួលលើសពី ៨០០$ មានចំនួន ២,៤% ខណៈមានអ្នកការធ្វើការងារស្របជំនាញលើសពី៥០% មានចំនួនជិត ៦០% និងទទួលបានឈ្នួលលើសពី ៨០០$ មានចំនួន ៥,៥%

## ៤.៤. គន្លងនិទ្ទេស (ឯកសារយោង) ដែលបានប្រើប្រាស់ក្នុងការសិក្សា


1. អនុក្រឹត្យស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា លេខ១៥៣ អនក្រ.បកចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤
2. សេចក្តីណែនាំលេខ៥០ អយក.សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
3. គោលការណ៍ណែនាំលេខ៦៥៥ ស.ភ.ន.វ.ស ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២២ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
4. លិខិតឧទ្ទេសនាមលេខ៧២៨ ស.ភ.ន.វ.ស ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
5. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ខែមីនា ឆ្នាំ២០១៦
6. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ខែធ្នូ ឆ្នាំ២០១៦
7. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៧
8. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៨
9. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ២០១៩
10. របាយការណ៍ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើរបស់និស្សិត ស.ភ.ន.វ.ស. ឆ្នាំ ២០២០

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ 1. គោលការណ៍ណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ...០៥៤...ស.ភ.ន.វ.ស

### គោលការណ៍ណែនាំ
### ស្តីពី
### ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
### នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ដើម្បីចូលរួមអនុវត្តសកម្មភាពគោលនយោបាយនៃផែនការយុទ្ធសាស្ត្រអប់រំ សំដៅពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនៅឧត្តមសិក្សា និងកាត់បន្ថយគម្លាតជំនាញរវាងការបណ្តុះបណ្តាលនៅឧត្តមសិក្សានិងតម្រូវការទីផ្សារ ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ស.ភ.ន.វ.ស.) បង្កើតគោលការណ៍ ស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានខ្លឹមសារដូចខាងក្រោម៖

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

គោលការណ៍នេះមានគោលបំណងប្រមូលព័ត៌មានគ្រឡប់ពីនិស្សិតក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ន.វ.ស. ដើម្បីយកទៅប្រើប្រាស់សម្រាប់កែលម្អគុណភាពអប់រំ ឱ្យឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុករបស់កម្មវិធីសិក្សា និងពិនិត្យតាមដានអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា និងភាពឆ្លើយតបនៃជំនាញដែលបានបណ្តុះបណ្តាលទៅនឹងទីផ្សារការងារ និងភាពប្រែប្រួលនៃស្ថានភាពការងាររបស់និស្សិតបន្ទាប់ពីបញ្ចប់ការសិក្សា។

**ប្រការ២.-**

គោលការណ៍នេះ មានវិសាលភាពអនុវត្តនៅ ស.ភ.ន.វ.ស.។

### ជំពូកទី២
### ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា

**ប្រការ៣.-**

ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា គឺជាការប្រមូលព័ត៌មានតាមរយៈការស្ទង់មតិជាទម្រង់សរសេរ ឬធ្វើបទសម្ភាសន៍ ជាមួយនិស្សិតដែលទើបបញ្ចប់ការសិក្សា និង/ឬក្នុងអំឡុងពេល

១

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

ណាមួយក្រោយបញ្ចប់ការសិក្សា។

**ប្រការ៤.-**

ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ចំនួននិស្សិតបញ្ចប់ការសិក្សា ដែលបំពេញការងារនៅបណ្តារាជធានី ខេត្ត និងក្រៅប្រទេស
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាដែលបានបង្កើតសហគ្រាសធុនតូច/មធ្យម នៅបណ្តារាជធានី ខេត្ត និងក្រៅប្រទេស
- ចំនួន/ភាគរយនៃនិស្សិតទទួលបានបរិមាណប្រាក់ចំណូលពីការចុះធ្វើកម្មសិក្សា
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារ ដែលមានកម្រិតប្រាក់បៀវត្ស ឬចំណូល ពី ៥ ទៅ ១០ដង បើប្រៀបធៀបទៅនឹងកម្មករដែលមិនមានជំនាញ
- ចំនួន/ភាគរយនៃនិស្សិតបញ្ចប់ការសិក្សាទទួលបានការងារ ជាអ្នកគ្រប់គ្រងកម្រិតកណ្តាល និងខ្ពស់នៅក្នុងក្រុមហ៊ុនឯកជន អង្គការអន្តរជាតិ និងភ្នាក់ងារផ្នែកកិច្ចសហប្រតិបត្តិការ។

## ជំពូកទី៣
## យន្តការសម្រាប់គ្រប់គ្រងការអនុវត្ត

**ប្រការ៥.-**

ស.ភ.ន.វ.ស. រៀបចំបង្កើតគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។

**ប្រការ៦.-**

សមាសភាពនៃគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា រួមមានដូចខាងក្រោម៖

**ក. គណៈកម្មការទទួលបន្ទុករួម**

- ប្រធាន ០១រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**ខ. អនុគណៈកម្មការគាំទ្រ**

- ប្រធាន ០១រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**គ. អនុគណៈកម្មការបច្ចេកទេស**

- ប្រធាន ០១ រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

២

ឃ. អនុគណៈកម្មការគណនេយ្យ

- ប្រធាន ០១ រូប
- អនុប្រធាន ០១ ឬច្រើនរូប
- សមាជិកមួយចំនួនតាមតម្រូវការការងារ

**ប្រការ៧.-**

គណៈកម្មការទទួលបន្ទុករួម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្រេចលើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យតាមដានលើការអនុវត្តការងាររបស់អនុគណៈកម្មការនានា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- រៀបចំបង្កើត ឬកែលំអកម្រងសំណួរដែលត្រូវប្រើប្រាស់ក្នុងការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានការចូលរួមពីអនុគណៈកម្មការនានា
- ពិនិត្យរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីអនុគណៈកម្មការគាំទ្រ
- រាយការណ៍ពីលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជូនប្រធានក្រុមប្រឹក្សាភិបាល
- បង្ហាញលទ្ធផលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកសំណើ និងការពារថវិកាកម្មវិធីវិនិយោគប្រចាំឆ្នាំ និងភាគីពាក់ព័ន្ធ ក្នុងការកៀគរកមូលនិធិសម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ៨.-**

អនុគណៈកម្មការគាំទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលក្នុងការបង្កើតក្រុមការងារបច្ចេកទេស ដោយមានឈ្មោះ និងកិច្ចការច្បាស់លាស់ ដែលមានការអនុម័តពីសាកលវិទ្យាធិការ
- ជួយកម្រិតគ្រប់គ្រង ក្នុងការពិនិត្យតាមដានលើការអនុវត្តការងារក្រុមការងារបច្ចេកទេសលើការងារសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- ប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយប្រើកម្រងសំណួរដែលបានកំណត់
- ប្រគល់ទិន្នន័យដែលប្រមូលបានខាងលើ ជូនអនុគណៈកម្មការបច្ចេកទេស
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីក្រុមការងារបច្ចេកទេស ជូនសាកលវិទ្យាធិការ ដើម្បីឯកភាព និងបោះពុម្ព

៣

- សម្របសម្រួលលើការរៀបចំកម្មវិធីផ្សព្វផ្សាយលទ្ធផលក្នុងគ្រឹះស្ថាន និងស្ថាប័នផ្សេងៗ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ៩.-**

អនុគណៈកម្មការបច្ចេកទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- បញ្ចូលទិន្នន័យនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យ និងវិភាគលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច
- ប្រៀបធៀប និងវិភាគការអនុវត្តកម្រិតកម្មវិធី និងពិនិត្យលើផលជះ នៃការកែលម្អគុណភាពអប់រំដែលបានមកពីកម្មវិធីធ្វើការវិនិយោគ និងមិនបានធ្វើការវិនិយោគ
- ធ្វើបទបង្ហាញផ្សព្វផ្សាយលទ្ធផលដែលទទួលបានក្នុងសាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**ប្រការ១០.-**

អនុគណៈកម្មការគណនេយ្យ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងរៀបចំគម្រោងថវិកាសម្រាប់ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

## ជំពូកទី៤
## ដំណើរការក្នុងការអនុវត្ត

**ប្រការ១១.-**

ការប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ត្រូវធ្វើឡើងក្នុងអំឡុងពេល៦ខែ ១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ សម្រាប់ជំនាន់នីមួយៗទៅតាមមុខជំនាញ បន្ទាប់ពីនិស្សិតបានបញ្ចប់ការសិក្សា។

**ប្រការ១២.-**

ក្រោយពីទទួលបានការសម្រេចលើកាលបរិច្ឆេទ នៃការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា អនុគណៈកម្មការគាំទ្រ ត្រូវចាប់ផ្ដើមដំណើរការប្រមូលទិន្នន័យក្នុងរយៈពេល៣សប្ដាហ៍ និងត្រូវបញ្ជូនទិន្នន័យដែលប្រមូលបានទៅអនុគណៈកម្មការបច្ចេកទេស។

**ប្រការ១៣.-**

អនុគណៈកម្មការបច្ចេកទេស ត្រូវរៀបចំបញ្ចូល វិភាគទិន្នន័យ និងសរសេររបាយការណ៍លទ្ធផលក្នុងរយៈពេល៣ខែ រួចប្រគល់ជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច។

៤

**ប្រការ១៤.-**

គណៈកម្មការទទួលបន្ទុករួម ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ក្នុងរយៈពេល១ខែ និងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។

## ជំពូកទី៥
## ផ្សព្វផ្សាយរបាយការណ៍លទ្ធផល និងប្រើប្រាស់លទ្ធផល

**ប្រការ១៥.-**

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល គណៈកម្មការទទួលបន្ទុករួម ត្រូវបោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជាមួយភាគីពាក់ព័ន្ធនៅក្នុង និងក្រៅសាកលវិទ្យាល័យ តាមរយៈសិក្ខាសាលា វេទិកាផ្សេងៗ បណ្តាញទំនាក់ទំនងសង្គម និងគេហទំព័ររបស់សាកលវិទ្យាល័យ។

សាកលវិទ្យាល័យ ត្រូវបញ្ជូនរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាទៅក្រសួងអាណាព្យាបាល ជារៀងរាល់ឆ្នាំ។

**ប្រការ១៦.-**

មហាវិទ្យាល័យ ថ្នាក់ក្រោយបរិញ្ញាបត្រ និងផ្នែកពាក់ព័ន្ធ ត្រូវយកលទ្ធផលដែលទទួលបានពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ទៅអភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាសម្រាប់មុខជំនាញដែលពាក់ព័ន្ធ និងកែលម្អកម្រងសំណួរស្រាវជ្រាវលើការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាសម្រាប់ប្រើប្រាស់នៅឆ្នាំបន្ទាប់។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៧.-**

គោលការណ៍នេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

**ចម្លងជូនៈ**

- គ្រប់អង្គភាពចំណុះ ស.ភ.ន.វ.ស. "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

៥

## ឧបសម្ព័ន្ធ 2. លិខិតឧទ្ទេសនាម

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
លេខ៣៧២៨...ស.ភ.ន.វ.ស

### លិខិតឧទ្ទេសនាម

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញ នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ក្នុងគោលបំណងប្រមូលព័ត៌មានត្រឡប់ពីនិស្សិតក្រោយបញ្ចប់ការសិក្សា ដើម្បីយកទៅប្រើប្រាស់សម្រាប់កែលម្អគុណភាពអប់រំឱ្យឆ្លើយតបទៅនឹងលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីសិក្សា ពិនិត្យតាមដានអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ភាពឆ្លើយតបនៃជំនាញដែលបានបណ្តុះបណ្តាលទៅនឹងទីផ្សារការងារ និងភាពប្រែប្រួលនៃស្ថានភាពការងាររបស់និស្សិតបន្ទាប់ពីបញ្ចប់ការសិក្សា។

**I. គណៈកម្មការទទួលបន្ទុករួម**

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត លុយ ចណ្ណា | សាកលវិទ្យាធិការ | ប្រធាន |
| ២. | លោក ឃិត សូរ្យច | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៣. | លោក ពៅ សារឿន | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៤. | បណ្ឌិត សឿន សោភ័ណ | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៥. | លោក ប៊ុន រស្មី | សាកលវិទ្យាធិការរង | អនុប្រធាន |
| ៦. | លោក ឈាង ម៉េងហៀក | ព្រឹទ្ធបុរស មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង | សមាជិក |
| ៧. | លោក គឹម សាវុន | ព្រឹទ្ធបុរសរង មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង | សមាជិក |

**II. អនុគណៈកម្មការគាំទ្រ**

| | | | |
|---|---|---|---|
| ៨. | លោក ងួន ហេង | ប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ៩. | លោក សៅ ស៊ីវុត្ថា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ១០. | លោក ឡាយ គង់ | អនុប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | សមាជិក |
| ១១. | លោក ឈាង ហ៊ុយ | អនុប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. | លោក ហោ បូលីន | គ្រូទទួលបន្ទុកថ្នាក់ | សមាជិក |

**III. អនុគណៈកម្មការបច្ចេកទេស** (បញ្ចូលទិន្នន័យ វិភាគ និងសរសេររបាយការណ៍)

| | | | |
|---|---|---|---|
| ១៣. | បណ្ឌិត ង៉ាន់ ស៊ុនដេត | ប្រធានដេប៉ាតឺម៉ង់គណនេយ្យ និងគ្រប់គ្រង | ប្រធាន |
| ១៤. | លោក សួន ចំរើន | ប្រធានការិយាល័យធានាគុណភាព | សមាជិក |

**១. គណៈកម្មការទទួលបន្ទុករួម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្រេចលើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យតាមដានលើការអនុវត្តការងាររបស់អនុគណៈកម្មការនានា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់

១

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

- រៀបចំបង្កើត ឬកែលំអកម្រងសំណួរដែលត្រូវប្រើប្រាស់ក្នុងការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលមានការចូលរួមពីអនុគណៈកម្មការនានា
- ពិនិត្យរបាយការណ៍លទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីអនុគណៈកម្មការគាំទ្រ
- រាយការណ៍ពីលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ជូនប្រធានក្រុមប្រឹក្សាភិបាល
- បង្ហាញលទ្ធផលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកសំណើ និងការពារថវិកាកម្មវិធីវិនិយោគប្រចាំឆ្នាំ និងភាគីពាក់ព័ន្ធ ក្នុងការកៀគរមូលនិធិសម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**២. អនុគណៈកម្មការគាំទ្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលក្នុងការបង្កើតក្រុមការងារបច្ចេកទេស ដោយមានឈ្មោះ និងកិច្ចការច្បាស់លាស់ ដែលមានការអនុម័តពីសាកលវិទ្យាធិការ
- ជួយកម្រិតគ្រប់គ្រង ក្នុងការពិនិត្យតាមដានលើការអនុវត្តការងារក្រុមការងារបច្ចេកទេស លើការងារសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយផ្អែកលើផែនការសកម្មភាពដែលបានកំណត់
- ប្រមូលទិន្នន័យនៃស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដោយប្រើកម្រងសំណួរដែលបានកំណត់
- ប្រគល់ទិន្នន័យដែលប្រមូលបានខាងលើ ជូនអនុគណៈកម្មការបច្ចេកទេស
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ដែលទទួលបានពីក្រុមការងារបច្ចេកទេស ជូនសាកលវិទ្យាធិការ ដើម្បីឯកភាព និងបោះពុម្ព
- សម្របសម្រួលលើការរៀបចំកម្មវិធីផ្សព្វផ្សាយលទ្ធផលក្នុងគ្រឹះស្ថាន និងស្ថាប័នផ្សេងៗ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

**៣. អនុគណៈកម្មការបច្ចេកទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- បញ្ចូលទិន្នន័យនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- ពិនិត្យ និងវិភាគលទ្ធផលនៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា
- រៀបចំរបាយការណ៍លទ្ធផល នៃការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាជូន សាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច
- ប្រៀបធៀប និងវិភាគការអនុវត្តកម្រិតកម្មវិធី និងពិនិត្យលើផលជះ នៃការកែលម្អគុណភាពអប់រំដែលបានមកពីកម្មវិធីធ្វើការវិនិយោគ និងមិនបានធ្វើការវិនិយោគ
- ធ្វើបទបង្ហាញផ្សព្វផ្សាយលទ្ធផលដែលទទួលបានក្នុងសាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធ។

ឯកឧត្តម លោក លោកស្រី ដូចមាននាយនាមខាងលើ ត្រូវបំពេញភារកិច្ចតាមការចាត់តាំងនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចន្ទា**

**កន្លែងទទួល**

- គ្រប់អង្គភាពចំណុះ ស.ភ.ន.វ.ស. "ដើម្បីមុខការ"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

២

## ឧបសម្ព័ន្ធ 3. គម្រូសំណួរស្រាវជ្រាវ

សួស្តីនិស្សិតដែលបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) សូមនិស្សិតដែលបានបញ្ចប់ការសិក្សាមេត្តាជួយឆ្លើយកម្រងសំណួរខាងក្រោមនេះដើម្បីឲ្យថ្នាក់ដឹកនាំសាកលវិទ្យាល័យទទួលបានព័ត៌មានជាក់លាក់ទាក់ទងនឹងការសិក្សា ប្រភេទការងារ ការសិក្សាបន្ថែម ឬសកម្មភាពផ្សេងទៀតចាប់តាំងពីអ្នកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនេះ។ ព័ត៌មានដែលអ្នកបានផ្តល់ជូនតាមរយៈកម្រងសំណួរនេះនឹងជួយដល់សាកលវិទ្យាល័យដើម្បីរៀបចំផែនការបណ្តុះបណ្តាល និងកែលម្អកម្មវិធីសិក្សានាពេលអនាគតឲ្យឆ្លើយតបតាមតម្រូវការទីផ្សារការងារ។ ចម្លើយដែលអ្នកបានផ្តល់ជូននឹងត្រូវរក្សាជាការសម្ងាត់។
សូមថ្លែងអំណរគុណចំពោះការចូលរួមសហការ!

**១-ព័ត៌មានផ្ទាល់ខ្លួន ៖**

- ភេទ : ☐ 1. ប្រុស ☐ 2. ស្រី
- ឆ្នាំកំណើត : …………………
- លេខទូរស័ព្ទ : …………………
- អ៊ីម៉ែល/ហ្វេសបុក : …………………
- អតីតសិស្សមកពីវិទ្យាល័យ : ………………… រាជធានី/ខេត្ត: …………………………
- អាសយដ្ឋានបច្ចុប្បន្ន :

………………………………………………………………………………………………

**២- ព័ត៌មានសិក្សា ៖**

*សូមបំពេញចម្លើយ ឬ គូសសញ្ញា ✓ ក្នុងប្រអប់នៃចម្លើយ*

១. តើអ្នកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញអ្វី?

☐1. គ្រប់គ្រងធុរកិច្ច

☐2. សេដ្ឋកិច្ចអភិវឌ្ឍន៍

☐3. គណនេយ្យ

☐4. ធនាគារ និងហិរញ្ញវត្ថុ

☐5. គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច

២. តើអ្នកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញខាងលើនៅឆ្នាំណា?

………………………………………………………………………………………………

៣. តើអ្នកបានចុះកម្មសិក្សា/ហាត់ការក្នុងអំឡុងពេលសិក្សាដែរឬទេ?

☐1. ចាស/បាទ

☐2. ទេ

៤. ករណីបានចុះកម្មសិក្សា/ហាត់ការ តើអ្នកទទួលបានប្រាក់ចំណូលចំនួនប៉ុន្មានក្នុង១ខែ?

☐1. មិនទទួលបានប្រាក់ចំណូល

☐2. តិចជាង ១០០$

☐3. ១០០$-២០០$

☐4. ច្រើនជាង ២០០$

## ៣. កម្មវិធីបណ្តុះបណ្តាល៖

*សូមគូសសញ្ញា ✓ ក្នុងតារាងនៃចម្លើយ*

១. សូមអ្នកជួយផ្តល់ចំណាត់ថ្នាក់លើ**បំណិន**ដែលទទួលបានពីកម្មវិធីបណ្តុះបណ្តាលក្នុងពេលសិក្សាដូចខាងក្រោម៖ (1=តិចតួចណាស់ 2=តិចតួច 3=មធ្យម 4=ច្រើន 5=ច្រើនណាស់)

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| ភាពច្នៃប្រឌិត | | | | | |
| ការធ្វើការងារជាក្រុម | | | | | |
| ការគិតពិចារណា | | | | | |
| ការដោះស្រាយបញ្ហា | | | | | |
| សហគ្រិនភាព | | | | | |
| ភាពជាអ្នកដឹកនាំ | | | | | |
| ការសម្រេចចិត្ត | | | | | |
| ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន | | | | | |
| ការប្រាស្រ័យទាក់ទង | | | | | |
| ភាសាអង់គ្លេស | | | | | |

២. តើអ្នកយល់ថាកម្មវិធីសិក្សាដែលបានបណ្តុះបណ្តាលមានការអនុវត្តផ្សារភ្ជាប់នឹងទ្រឹស្តីកម្រិតណា?

☐1. ពុំមាន

☐2. មានតិចតួច

☐3. មានកម្រិតមធ្យម

☐4. មានច្រើន

☐5. ច្រើនណាស់

៣. តើកម្មវិធីសិក្សានៅ RULE អាចឆ្លើយតបតម្រូវការទីផ្សារការងារបានកម្រិតណា?

☐1. ពុំមាន

☐2. មានតិចតួច

☐3. មានកម្រិតមធ្យម

☐4. មានច្រើន

☐5. ច្រើនណាស់

**៤. ស្ថានភាពការងារ ៖**

*សូមបំពេញចម្លើយ ឬ គូសសញ្ញា ✓ ក្នុងប្រអប់នៃចម្លើយ*

១. តើអ្នកមានការងារធ្វើយ៉ាងដូចម្ដេច នាបច្ចុប្បន្ននេះ?

☐1. មានការងារធ្វើ

☐2. អាជីវកម្មផ្ទាល់ខ្លួន

☐3. នៅសិក្សាបន្ត

☐4. មានការងារធ្វើផង និងមានអាជីវកម្មផ្ទាល់ខ្លួន

☐5. មានការងារធ្វើផង និងសិក្សាបន្ត

☐6. ព្រះសង្ឃ

☐7. មិនទាន់មានការងារ

☐8. ផ្សេងៗ

២. ករណីអ្នកមានការងារធ្វើ តើការងារពេញម៉ោង ឬមិនពេញម៉ោង?

☐1. ការងារពេញម៉ោង

☐2. ការងារមិនពេញម៉ោង

៣. ករណីអ្នកមានអាជីកម្មផ្ទាល់ខ្លួន តើជាប្រភេទអាជីកម្មមួយណា?

☐1. សហគ្រាសធុនតូចផ្ទាល់ខ្លួន

☐2. សហគ្រាសធុនមធ្យមផ្ទាល់ខ្លួន

☐3. សហគ្រាសធុនធំផ្ទាល់ខ្លួន

☐4. ផ្សេងៗ

៤. ករណីអ្នកបានចុះកម្មសិក្សា/ហាត់ការ តើអ្នកទទួលបានការងារធ្វើនៅកន្លែង ដែលអ្នកបានចុះកម្មសិក្សា/ហាត់ការដែរឬទេ?

☐1. បាន

☐2. មិនបាន

៥. តើអ្នកធ្វើការងារក្នុងស្ថាប័នប្រភេទណា?

☐1. រដ្ឋ

☐2. ឯកជន

☐3. អង្គការជាតិ

☐4. អង្គការអន្តរជាតិ

☐5. ភ្នាក់ងារសហប្រតិបត្តិការ

☐6. ផ្សេងៗ

៦. តើអ្នកបម្រើការងារក្នុងឋានៈប្រភេទណា?

☐1. បុគ្គលិកធម្មតា

☐2. បុគ្គលិកបច្ចេកទេស

☐3. អ្នកគ្រប់គ្រងកម្រិតកណ្តាល

☐4. អ្នកគ្រប់គ្រងកម្រិតខ្ពស់

៧. តើអ្នកចំណាយពេលប៉ុន្មានខែដើម្បីទទួលបានការងារធ្វើ/បង្កើតសហគ្រាសផ្ទាល់ខ្លួន បន្ទាប់ពីបានបញ្ចប់ការសិក្សា?

☐1. មានការងារធ្វើ/បង្កើតសហគ្រាសផ្ទាល់ខ្លួន មុនពេលបញ្ចប់ការសិក្សា

☐2. តិចជាងឬស្មើ ១ខែ

☐3. លើសពី១ខែ ទៅ ៣ខែ

☐4. លើសពី៣ខែ ទៅ ៦ខែ

☐5. លើសពី៦ខែ ទៅ ៩ខែ

☐6. លើសពី៩ខែ ទៅ ១២ខែ

☐7. ច្រើនជាង១២ខែ

៨. តើការងារ/សហគ្រាសផ្ទាល់ខ្លួន របស់អ្នក មានទីតាំងនៅទីណា?

☐1. រាជធានីភ្នំពេញ

☐2. ខេត្ត.........

☐3. ក្រៅប្រទេស

****សម្រាប់ការជ្រើសរើសចម្លើយ(2) សូមបញ្ជាក់ឈ្មោះខេត្ត**

៩. តើអ្នកធ្វើការ/បង្កើតសហគ្រាសផ្ទាល់ខ្លួន ស្របនឹងជំនាញដែលខ្លួនបានបញ្ចប់ការសិក្សាដែរឬទេ?

☐1. ត្រូវជំនាញ១០០%

☐2. ត្រូវជំនាញលើសពី៥០%

☐3. ត្រូវជំនាញតិចជាង៥០%

☐4. មិនត្រូវជំនាញ

១០. ករណីអ្នកធ្វើការងារមិនត្រូវជំនាញ តើបណ្តាលមកពីកត្តាអ្វីសំខាន់ជាងគេ?

☐1. ប្រាក់ឈ្នួលច្រើន

☐2. ទីផ្សារពលកម្មចង្អៀត

☐3. មានអាជីវកម្មផ្ទាល់ខ្លួន

☐4. តាមតម្រូវការទីផ្សារ

☐5. ចំណង់ចំណូលចិត្ត

☐6. ផ្សេងៗ

១១. តើអ្នកទទួលបានប្រាក់ចំណូលចំនួនប៉ុន្មានក្នុង១ខែ?

☐1. តិចជាង ២០០$

☐2. ២០០$ - ៤០០$

☐3. ៤០១$- ៦០០$

☐4. ៦០១$- ៨០០$

☐5. ៨០១$- ១០០០$

☐6. ច្រើនជាង ១០០០$

១២. ករណីមិនទាន់មានការងារធ្វើ តើបណ្តាលមកពីកត្តាអ្វី?

☐1. ពិបាករកការងារ

☐2. ការងារខុសជំនាញ

☐3. កំពុងរៀនបន្ត

☐4. មានគ្រួសារ

☐5. ផ្លាស់ប្តូរទីលំនៅ

☐6. ផ្សេងៗ

## ៥. តម្រូវការមុខជំនាញ៖

១. តើអ្នកយល់យ៉ាងណាចំពោះតម្រូវការជំនាញ សម្រាប់ការងារដែលខ្លួនកំពុងធ្វើបច្ចុប្បន្ននេះ?
(1=មិនចាំបាច់ 2=ចាំបាច់តិចតួច 3=ចាំបាច់មធ្យម 4=ចាំបាច់បង្គួរ 5=ចាំបាច់ណាស់)
*(ប្រសិនបើអ្នកមិនមានការងារធ្វើពេលបច្ចុប្បន្ននេះទេ សូមកុំបំពេញផ្នែកនេះ)*

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| សមត្ថភាពបង្កើតគំនិត និងដំណោះស្រាយថ្មីៗ | | | | | |
| សមត្ថភាពសម្របខ្លួនតាមការផ្លាស់ប្តូរ | | | | | |
| ការគិតត្រិះរិះ | | | | | |
| សមត្ថភាពធ្វើការដើម្បីឆ្ពោះទៅរកគោលដៅ | | | | | |
| សមត្ថភាពធ្វើការងារជាក្រុម | | | | | |
| សមត្ថភាពទំនាក់ទំនង (ទាំងការនិយាយ និងសរសេរ) | | | | | |
| ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន | | | | | |
| ភាពជាអ្នកដឹកនាំ | | | | | |

២. តាមទស្សនៈរបស់អ្នក តើការបំពេញការងារបច្ចុប្បន្ន បានប្រើប្រាស់ចំណេះដឹងកម្រិតណា?

☐1. ប្រើប្រាស់ចំណេះដឹងទាបជាងកម្រិតសញ្ញាបត្រ

☐2. ប្រើប្រាស់ចំណេះដឹងត្រូវនឹងកម្រិតសញ្ញាបត្រ

☐3. ប្រើប្រាស់ចំណេះដឹងខ្ពស់ជាងកម្រិតសញ្ញាបត្រ

## ៦. ព័ត៌មានត្រឡប់ ៖

១. តើអ្នក គិតថាសាកលវិទ្យាល័យបានជួយអ្នកកម្រិតណា ដើម្បីទទួលបានការងារ?

☐1. មិនបានជួយ

☐2. បានជួយតិចតួច

☐3. បានជួយមធ្យម

☐4. បានជួយបង្គួរ

☐5. បានជួយច្រើន

២. តើអ្នកបានទទួលការបណ្ដុះបណ្ដាលបន្ថែមពីកន្លែងការងារបច្ចុប្បន្នរបស់អ្នកដែរឬទេ?

☐1. បានទទួល

☐2. មិនបានទទួល

៣. ប្រសិនបើបានទទួលការបណ្ដុះបណ្ដាល តើអ្នកត្រូវបានផ្ដល់ការបណ្ដុះបណ្ដាលអ្វីបន្ថែម?

……………………………………………………………………………………………………

៤. អ្នកបាន និងកំពុងសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត និង/ឬបរិញ្ញាបត្រជាន់ខ្ពស់ដែរឬទេ?

☐1. បានសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត

☐2. បានសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់

☐3. បានសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត និងបរិញ្ញាបត្រជាន់ខ្ពស់

☐4. មិនបានបន្តការសិក្សា

៥. តើអ្នកបាន និងកំពុងសិក្សាកម្រិតបរិញ្ញាបត្រផ្សេងទៀត និង/ឬបរិញ្ញាបត្រជាន់ខ្ពស់លើមុខជំនាញអ្វី?

……………………………………………………………………………………………………

៦. តើអ្នកបាន និងកំពុងសិក្សាជំនាញខ្លីៗដែរឬទេ?

☐1. បានសិក្សា និងបញ្ចប់ដោយជោគជ័យ

☐2. កំពុងសិក្សា

☐3. មិនបានបន្តការសិក្សា

៧. តើអ្នកបានចូលរួមក្នុងសកម្មភាពសង្គមបានកម្រិតណា ក្រោយបញ្ចប់ការសិក្សានៅ RULE?

☐1. ពុំមាន

☐2. មានតិចតួច

☐3. មានកម្រិតមធ្យម

☐4. មានច្រើន

☐5. ច្រើនណាស់

៧. យោបល់ស្ថាបនា ប្រសិនបើមាន។

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………………… .

**សូមអរគុណចំពោះការសហការ**!